# ប្រវត្តិគំនិតនយោបាយ បស្ចិមប្រទេស

# History of Western Political Ideas





អ៊ុំ ប៊ុម

Editions Angkor

www.elibraryofcambodia.org

www.elibraryofcambodia.org

# ឯកសារជំនួយស្មារតី

# ប្រវត្តិគំនិតនយោបាយ

# បស្ចិមប្រទេស

## History of Western Political Ideas

រៀបរៀងដោយៈ

អ៊ុំ ប៊ុំម

ព្រះរាជាណាចក្រកម្ពុជា
8618/08
3/4
បណ្ណាល័យជាតិ

ចាត់ចែងបោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ

Editions Angkor

២០០៨

National Library of Cambodia
00013622 www.elibraryofcambodia.org

© រក្សាសិទ្ធគ្រប់យ៉ាង

បោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពផ្សាយ **អង្គរ** ( Editions Angkor )

ISBN - 13-978-99950-2-059-0

២០០៨

www.elibraryofcambodia.org

# ប្រវត្តិគំនិតនយោបាយ

# បស្ចិមប្រទេស

រៀបរៀងដោយៈ

## អ៊ុំ ប៉ុម

## ការីកុំព្យូទ័រ ៈ រិទ្ធ រីតា



www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្ភកថា

**មិត្តអ្នកអានជាទីមេត្រី !**

"ប្រវត្តិគំនិតនយោបាយ" គឺជាផ្នែកមួយ ក្នុងចំណោមផ្នែកទាំងបួននៃមុខវិជ្ជា វិទ្យាសាស្ត្រនយោបាយមួយ ដែលសកលលោកសព្វថ្ងៃ កំពុងយកចិត្តទុកដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមមហាវិទ្យាល័យនានា ។

ជាទូទៅ ក្នុងការសិក្សារៀនសូត្រពី ប្រវត្តិគំនិតនយោបាយ គេតែងតែទទួលបាននូវគោលគំនិតសំខាន់ៗ ដែលតួអង្គទាំងឡាយជាទស្សនវិទូ រដ្ឋបុរស ឬ អ្នកគិតគូរខាងនយោបាយបានលើកឡើង ហើយគោលគំនិតទាំងអស់នោះ អាចក្លាយទៅជាមូលដ្ឋាននៃការគិតគូរដ៏មានសារៈសំខាន់ សំរាប់បំរើឱ្យការត្រិះរិះពិចារណា ក្នុងនយោបាយដឹកនាំ និងគ្រប់គ្រងប្រទេស ។ ប៉ុន្តែ គេគប្បីចងចាំថាការសិក្សារៀនសូត្រពីប្រវត្តិគំនិតនយោបាយ មិនមែនជាការសិក្សារៀនសូត្រដោយគ្រាប់តាមគោលគំនិតពីខាងក្រៅទាំងស្រុង ហើយយកមកអនុវត្តដោយងងឹតងងុលខុសទំនងនៅក្នុងនយោបាយដឹកនាំ និងគ្រប់គ្រងប្រទេសជាតិរបស់ខ្លួននោះឡើយ។ផ្ទុយទៅវិញគេគប្បី



www.elibraryofcambodia.org

យកគោលគំនិតដែលរៀនសូត្របាន មកធ្វើការថ្លឹងថ្លែង និង វិភាគ ប្រកបដោយគតិបណ្ឌិត ទៅតាមស្ថានភាពជាក់ស្តែងនៃ ទីតាំងភូមិសាស្ត្រ កាលៈទេសៈ ចិត្តសាស្ត្រ និងប្រពៃណី ទំនៀមទម្លាប់របស់សង្គមជាតិនីមួយៗ ទើបការអនុវត្តន៍នោះទទួលបាននូវផ្លែផ្កា ហើយចៀសផុតពីគ្រោះថ្នាក់នៃជម្ងឺ "គម្ពីរនិយមស្លាប់ក្រឡា" ។

ម្យ៉ាងទៀត ក្នុងការរៀបចំចងក្រងជាសៀវភៅស្តីពី "ប្រវត្តិគំនិតនយោបាយបស្ចិមប្រទេស" នេះឡើងរូបខ្ញុំផ្ទាល់ បានចាប់ផ្តើមសិក្សាស្រាវជ្រាវតាំងពីឆ្នាំ២០០១ មកម្ល៉េះ ហើយក៏បានប្រើប្រាស់នូវវិធីសាស្ត្រជាក់ស្តែងមួយចំនួនដូចជា ប្រមូលផ្តុំនូវគោលគំនិតរបស់តួអង្គ ដោយផ្សារភ្ជាប់ទៅនឹងការសិក្សាស្វែងយល់បន្ថែមអំពីជីវប្រវត្តិរបស់តួអង្គនីមួយ ៗ ដែលជាម្ចាស់គំនិតព្រមទាំងបានបង្ហាញឱ្យឃើញពីសង្គមបរិយាកាស ដែលតួអង្គទាំងនោះបានឆ្លងកាត់ ពីព្រោះខ្ញុំយល់ថា សង្គមបរិយាកាសគឺជាកត្តាដ៏សំខាន់មួយដែលជះឥទ្ធិពលដល់ផ្នត់គំនិត និងការគិតគូររបស់តួអង្គ ហើយក៏ជាប្រភព នៃការបង្កើតឡើងនូវគោលគំនិតអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីយកទៅដោះស្រាយបញ្ហាសង្គមដែលកើតមានឡើង ។

នៅទីបញ្ចប់នៃអារម្ភកថា ក្នុងនាមជាអ្នករៀបរៀងស្នាដៃដ៏ស្តួចស្តើងនេះ ខ្ញុំសូមខន្តីអភ័យទោសជាមុនពីសំណាក់មិត្តអ្នកអាន


www.elibraryofcambodia.org

ចំពោះការប្រើប្រាស់ឈ្មោះតួអង្គ ឬឈ្មោះផ្សេងៗ ទៅតាមសូរស័ព្ទនៃភាសាបារាំងដែលធ្វើឱ្យមិត្តអ្នកអានជាពិសេសយុវវ័យមានកង្វល់ក្នុងការសិក្សាស្វែងយល់បន្ថែមទៀត ទៅលើឈ្មោះអស់ទាំងនោះតាមសូរស័ព្ទនៃភាសាអង់គ្លេស ស្របទៅតាមការនិយមចូលចិត្តរបស់ខ្លួននាពេលបច្ចុប្បន្ន ។

សូមមិត្តអ្នកអានទទួលបាននូវបញ្ញាញាណភ្លឺថ្លាក្នុងការបង្កើតជាគំនិតថ្មីៗ ដើម្បីរួមចំណែកថែរក្សាការពារ និងអភិវឌ្ឍសង្គមជាតិយើងឆ្ពោះទៅរកជោគជ័យដ៏ត្រចះត្រចង់នាពេលអនាគត !

**រាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨**

**អ្នករៀបរៀង**

**អ៊ឹ ប៊ុម**



www.elibraryofcambodia.org

www.elibraryofcambodia.org

## ដូចម្តេចដែលហៅថានយោបាយ ?

### I. និយមន័យពាក្យ"នយោបាយ"

១.ដើមកំណើតពាក្យ "នយោបាយ"

ពាក្យ "នយោបាយ" មានន័យទូលំទូលាយណាស់ ។ ពាក្យនេះមានដើមកំណើតចេញមកពីភាសាក្រិកបូរាណថា**Polis** ប្រែមកជាភាសាខ្មែរថា បូរីឬរដ្ឋ ។ ក្រៅពីពាក្យ **Polis** គេឃើញមានពាក្យ Politikos ដែលជាពាក្យសំរាប់សំគាល់បុគ្គលរស់នៅក្នុងបូរី ។ ក្នុងការរស់នៅ បុគ្គលម្នាក់ៗតែងមានទំនាក់ទំនងគ្នាដ៏ស្មុគស្មាញ ។ គេហៅទំនាក់ទំនងរបៀបនេះថា **Politika** ត្រូវគ្នាជាមួយនឹងភាសាអង់គ្លេសថា **Politic** ហើយភាសាខ្មែរយើងប្រែថា "នយោបាយ" ។

**២.និយមន័យជាក់ស្តែងមួយចំនួននៃពាក្យ"នយោបាយ"**

- និយមន័យរបស់លោក**ប្លាតុង**(៤២៨_៣៤៧BC)

ក្នុងសៀវភៅមួយឈ្មោះ Le Politique លោកប្លាតុងបានផ្តល់និយមន័យ"នយោបាយ" យ៉ាងដូច្នេះថា "នយោបាយ គឺជា



www.elibraryofcambodia.org

សិល្បៈដើម្បីចិញ្ចឹមហ្វូង" (La politique est l'art d'élever les troupeaux )។ លោកបានគូសបញ្ជាក់បន្តទៀតថា"..គឺហ្វូងសត្វដែលដំបូងឡើយ ត្រូវបានបែងចែកជាសត្វស្គាល់ផង និងមិនស្គាល់ផងហើយសត្វទាំងនោះមានជើងពីរ និងជើងបួន" (..Les troupeaux se divisant d'abord en bêtes connues et non connues , puis en bipèdes et en quadrupèdes)។ លោកបានបញ្ជាក់ បន្ថែមថា "នយោបាយគឺជាសិល្បៈសំរាប់ដឹកនាំសត្វជើងពីរ ដែលគ្មានស្នែង និង គ្មានស្លាប" ( La politique est l'art de gouverner les bipèds sans cornes et sans plumes ) ។ លោកបានគូសបញ្ជាក់ទៀតថា "នយោបាយគឺជា ចំណេះដឹងផ្នែកទ្រឹស្តីសំរាប់អប់រំជារួមចំពោះមនុស្សទូទៅ" ( La politique est une connaissance spéculative destinée à l'éducation communes des hommes ) ។ ពេលខ្លះទៀតលោកបានផ្តល់និយមន័យ " នយោបាយ " ថាជា "សិល្បៈនៃការដឹកនាំសង្គមមនុស្ស" "នយោបាយ" គឺជា "សិល្បៈ (ភាពប៉ិនប្រសប់) សំរាប់ដឹកនាំ ឬ គ្រប់គ្រងមនុស្ស ដោយធ្វើឱ្យមនុស្សជឿជាក់ប្រកបដោយក្តី ស្រុះ ស្រួលគ្នា" ( La politique est l'art de gouverner en persuadant les hommes avec leur consentement ) ។ ដូច្នេះ តាមនិយមន័យនេះ



www.elibraryofcambodia.org

បើគ្មានក្តីជឿជាក់ និង ភាពស្រុះស្រួលគ្នា ពីក្នុងចំណោមមនុស្សទាំងឡាយទេ គេមិនអាចហៅថា "នយោបាយ" បានឡើយ ។

សរុបមក តាមទស្សនៈរបស់លោកឡាតុង នយោបាយ គឺជាភាពប៉ិនប្រសប់ផង និងជាចំណេះដឹងផ្នែកទ្រឹស្តីផង សំរាប់ដឹកនាំគ្រប់គ្រងអប់រំមនុស្ស ធ្វើឱ្យមនុស្សមានក្តីជឿជាក់ ឬ ស្រុះស្រួលគ្នាទៅលើអ្វីមួយ ។

- និយមន័យរបស់លោក**អារីស្តូត**(៣៨៤-៣២២B.C)

ក្នុងសៀវភៅឈ្មោះ Politika លោកអារីស្តូតដែលជាទស្សនវិទូ និងជាអ្នកនយោបាយរបស់ក្រិកបូរាណបានឱ្យនិយមន័យថា "មនុស្សតាមធម្មជាតិគឺជាសត្វនយោបាយ"(Man by Nature is a political animal ) ។ ក្នុងឃ្លានេះ លោកចង់បញ្ជាក់ពីភាពចាំបាច់នៃទំនាក់ទំនងរបស់មនុស្សក្នុងសង្គម មានន័យថាក្នុងសង្គមនីមួយៗ មនុស្សមិនអាចរស់នៅដាច់តែឯងបានទេ ពោលគឺសុទ្ធតែមានការប្រាស្រ័យទាក់ទងគ្នា ហើយដែលលោកយល់ថាទំនាក់ទំនងទាំងអស់នោះ មានលក្ខណៈជានយោបាយទាំងអស់ ។ លោកបានគូសបញ្ជាក់តទៅទៀតថា មនុស្សទាំងអស់ពុំអាចមានកំរិតនយោបាយស្មើគ្នាបានទេ ។ អ្នកខ្លះមានកំរិតនយោបាយខ្ពស់ អ្នកខ្លះ មានកំរិតនយោបាយទាបជាង ។ លោកបានបញ្ជាក់តាម



www.elibraryofcambodia.org

ឃ្លាមួយទៀតថា "នយោបាយ គឺជាសិល្បៈនៃការដឹកនាំគ្រប់គ្រងមនុស្សដែលរស់នៅជាលក្ខណៈសង្គម" ( c'est l'art de gouverner les hommes vivant en société ) ។ លោកបានបញ្ជាក់ តាមឃ្លាមួយទៀតថា "នយោបាយ គឺជាវិទ្យាសាស្ត្រដែលទាក់ទងដល់ភាពថ្កុំថ្កើងរុងរឿង សម្បូណ៌សប្បាយរបស់មនុស្ស និង បុរី ទាំងមូល ។

• និយមន័យនៃពាក្យ"**នយោបាយ**"ពីចន្លោះសតវត្សទី១៦-២០

ចាប់ពីសតវត្សទី១៦-២០ ពាក្យ"នយោបាយ" ត្រូវបានគេយល់ឃើញដោយស៊ីជំរៅជាងមុន ។

- លោក**ហ្សង់បូដាំង** (Jean Bodin១៥៣០-១៥៩៦) ជាទស្សនវិទូ និង ជាអ្នកច្បាប់ជនជាតិបារាំង បានឱ្យនិយមន័យ "នយោបាយ" ដោយភ្ជាប់នយោបាយទៅនឹងច្បាប់ ។ លោកបានបញ្ជាក់ទៀតថា នយោបាយ គឺជាការរៀបចំស្ថាប័ននានា ក្នុងទំនាក់ទំនងជាមួយច្បាប់ ។

- លោក**ម៉ុងតេសគីយើ** (Montesquieu ១៦៨៩-១៧៦៦) បានឱ្យនិយមន័យពាក្យ "នយោបាយ" ទាក់ទងទៅនឹងគ្រប់មុខងាររបស់រដ្ឋាភិបាលដែលមានទំនាក់ទំនងទៅនឹងច្បាប់ទាំងក្នុងអង្គនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ និងអង្គការវិនិច្ឆ័យទោសគឺជា "នយោបាយ" ។



www.elibraryofcambodia.org

- និយមន័យរបស់វចនានុក្រម **Shorter Oxford English** បានសរសេរយ៉ាងដូច្នេះថា "នយោបាយគឺជាវិទ្យាសាស្ត្រ និង ជាសិល្បៈរបស់រដ្ឋាភិបាល" ( The science and art of the government ) ។ នយោបាយ គឺជា វិទ្យាសាស្ត្រដែលទាក់ទងទៅនឹងទ្រង់ទ្រាយ (រូបភាព) អង្គការចាត់តាំង និងរដ្ឋបាលរបស់រដ្ឋមួយ ឬចំណែកណាមួយរបស់រដ្ឋជាមួយនឹងការធ្វើនិយ័តកម្ម ទំនាក់ទំនងនោះជាមួយរដ្ឋដទៃ ( The science dealing with the form, organization and administration of a state or part of one and with regulation of its relations with other states ) ។

សរុបមករាល់គំនិតទាំងឡាយ ដែលបានរៀបរាប់ខាងលើ "នយោបាយ" បានផ្សារភ្ជាប់ទៅនឹង**មនុស្ស** (ការប្រាស្រ័យទាក់ទងគ្នា) **រដ្ឋ** (រដ្ឋាភិបាល) **ច្បាប់** និង **សង្គម** ។

## II. គោលបំណងរបស់នយោបាយ

បើតាមទស្សនៈរបស់លោកអារីស្តូត ដែលបានលើកឡើងរួចមកហើយថា "នយោបាយ គឺជាវិទ្យាសាស្ត្រដែលទាក់ទងដល់ភាពថ្កុំថ្កើងរុងរឿងសម្បូណ៌សប្បាយរបស់មនុស្ស និង បុរីទាំងមូល" ។ ដូច្នេះតាមទស្សនៈនេះ គោលបំណងចុងក្រោយរបស់នយោបាយ


www.elibraryofcambodia.org

គឺធ្វើឱ្យសង្គមមនុស្ស មានសុភមង្គល មានសេចក្ដីសុខសប្បាយ និង សម្បូណ៌រុងរឿង ។


www.elibraryofcambodia.org

## មាតិកាអត្ថបទ

ទំព័រ

១. លោកជ្រេកូ.......................................១-២
២. លោកសូឡុង.......................................៣-៥
៣. លោកគ្លីធីនីស ......................................៦-៧
៤. លោកប៉េរីគ្លីស ......................................៨-១១
៥. លោកហេរ៉ូដូត.......................................១២-១៥
៦. លោកអ៊ីប៉ូដាម ដឺមីឡេ .............................១៦-២០
៧. លោកសេណូហ្វុង ...................................២១-២៦
៨. លោកប្លាតុង .........................................២៧-៤០
៩. លោកអារីស្តូត .....................................៤១-៥២
១០. លោកប៉ូលីប.......................................៥៣-៥៨
១១. លោកស៊ីសេរ៉ុង ...................................៥៩-៦៧
១២. លោកសាំងអូហ្គូស្តាំង..............................៦៨-៧៤



www.elibraryofcambodia.org

១៣. លោកសាំងតូម៉ាស់ដាកាំង ..............................៧៥-៨១

១៤. លោកម៉ាគីយ៉ាវែល ..............................៨២-៩២

១៥. លោកហ្សង់បូដាំង ..............................៩៣-៩៦

១៦. លោកថូម៉ាស់ហូបស៍ ..............................៩៧-១០៣

១៧. លោកចនឡុក..............................១០៤-១០៩

១៨. លោកម៉ុងតេសគីយើ..............................១១០-១១៦

១៩. លោកហ្សង់ហ្សាក់រូសូ..............................១១៧-១២៦

២០. លោកអាដាមស្មីត..............................១២៧-១៣៤

២១. លោកអ៊ីម៉ានុយអែលខាន្ត..............................១៣៥-១៣៩

២២. លោកអេដម៉ាន់ បើក..............................១៤០-១៤៥

២៣. លោកជើរ៉េមី បេនថាំ..............................១៤៦-១៥១

២៤. លោកអាឡិចស៊ីសដឺតុកកឺវីល..............................១៥២-១៥៩

២៥. លោកចនស្ទួតមីល ..............................១៦០-១៦៧

ឯកសារពិគ្រោះ ..............................១៦៨-១៦៩



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកដ្រាកូ(Draco)

## I. លោកដ្រាកូ(Draco) :



គេពុំបានដឹង អំពីកាលបរិច្ឆេទនៃការកើត និងស្លាប់របស់លោក និងប្រវត្តិរបស់លោកច្បាស់លាស់ទេ ប៉ុន្តែគេគ្រាន់ តែដឹងថាលោកកើតនៅក្នុង ត្រកូលអភិជន ។

ក្នុងឆ្នាំ៦២១មុនគ.សលោកបានសរសេរជាលើកដំបូងនូវក្រមច្បាប់(Code of Laws) ដែលជាក្រមច្បាប់ដ៏តឹងរ៉ឹងបំផុត ។ សព្វថ្ងៃនេះពាក្យ Draconic ត្រូវបានគេប្រើសំរាប់សំគាល់នូវអ្វីដែលតឹងរ៉ឹង (Severe) ។

ក្រមច្បាប់ទាំងនេះត្រូវបានចារដោយឈាម ពោលគឺមិនសរសេរ ដោយទឹកខ្មៅធម្មតាទេ ( They were written in blood not in ink ) ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ក្រោយមក



www.elibraryofcambodia.org

គឺក្នុងពេលដែលក្រមច្បាប់ទាំងនោះ ត្រូវបានគេយកមកសរសេរជាលាយលក្ខណ៍អក្សរដោយទឹកខ្មៅនៅលើក្រដាស ចៅក្រមទាំងឡាយដែលតំណាងឱ្យពួកអភិជន ពុំបានយកក្រមច្បាប់ទាំងនោះមកអនុវត្តដោយខ្ជាប់ខ្ជួនដើម្បីការពារវណ្ណៈរបស់ខ្លួន និងធ្វើឱ្យវណ្ណៈរបស់ ខ្លួនរីកចំរើនឡើយ ។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកសូឡុង(Solon)

## ៦៣៨?-៥៥៩ មុនគ.ស

លោកត្រូវបានគេចាត់ទុកថាជា នីតិនិពន្ធមួយរូបប្រកបដោយគតិបណ្ឌិត (Wise legislator) ។



### ១-ជីវប្រវត្តិសង្ខេប

-លោកគឺជារដ្ឋបុរសម្នាក់ប្រចាំនៅបូរីអាតែន(Athènes)

-លោកគឺជាអ្នកតែងច្បាប់ដ៏ល្បីល្បាញ (នីតិនិពន្ធ) ។

- លោកជាអ្នកបង្កើតឡើងនូវ "លទ្ធិប្រជាធិបតេយ្យ" សំរាប់ទីក្រុងអាតែន ។

- លោកកើតក្នុងត្រកូលអភិជន ។

- កាលនៅពីក្មេង លោកបានចូលប្រឡូកក្នុងកិច្ចការជំនួញជាមួយបរទេស ជាហេតុធ្វើឱ្យលោកសន្សំបាននូវ បទពិសោធន៍ដ៏មានតម្លៃជាច្រើន ។



www.elibraryofcambodia.org

- ជាអ្នកកំណាព្យលេខមួយរបស់បូរីអាតែន។ ខ្លឹមសារទាំងនោះមានអត្ថន័យបំរើឱ្យគោលនយោបាយរបស់លោកទាំងអស់ ។

- គេសង្កេតឃើញក្នុងជីវិតសកម្មភាពដឹកនាំរបស់លោក មានវិបត្តិសង្គម និងសេដ្ឋកិច្ចមួយបានកើតឡើងក្នុងប្រទេសក្រិក ទាំងមូល : ការស្រុតចុះផ្នែកកសិកម្ម (Agricultural Depression) ដែលជាហេតុធ្វើឱ្យកសិករក្តៅក្រហាយពុំព្រមសងបំណុល ។

- ប្រឈមមុខនឹងបញ្ហាបែបនេះ ក្នុងឆ្នាំ៥៩៤មុនគ.ស លោកបានសរសេរឡើងវិញនូវក្រមច្បាប់របស់ដ្រេកូ ក្នុងគោលបំណងដើម្បីធ្វើឱ្យលក្ខខ័ណ្ឌនៃជីវភាពរស់នៅរបស់អ្នកក្រខ្សត់ បានល្អប្រសើរឡើងវិញហើយចេញផុតពីរូបភាពជិះជាន់គាបសង្កត់គ្រប់ប្រភេទ ។

## ២-គំនិតនយោបាយជាវិធានការណ៍

គំនិតនយោបាយជាវិធានការណ៍ទាំងនោះមាន :

- កាត់បន្ថយនូវបរិមាណទាសករពីប្រាក់បំណុល ( No more enslavement for debt ) ។
- លុបបំបាត់នូវការខ្ចីប្រាក់ដោយយកដីទៅបញ្ចាំ
- កំរិតដីដែលជាកម្មសិទ្ធិផ្ទាល់របស់ពួកអភិជន



www.elibraryofcambodia.org

- ពលរដ្ឋទាំងអស់ ទោះបីជាក្រីក្រយ៉ាងណាក៏ដោយ ក៏អាចចូលរួមក្នុងអង្គនីតិបញ្ញត្តិបាន ដូចជាពួក Thete ដែលជាទូទៅជាពួកគ្មានទ្រព្យសម្បត្តិ អាចចូលរួមក្នុងអង្គសភាបាន ពីព្រោះលោកយល់ថា បើការជ្រើសរើសមានលក្ខណៈទូលាយបែបនេះ ( ក្រៅពីរង្វង់ពលរដ្ឋអាតែន ) អាចធ្វើឱ្យប្រជាជនទាំងអស់ត្រួតពិនិត្យបាននូវការងាររបស់រដ្ឋាភិបាល ។

- បង្កើតវណ្ណៈថ្មីបន្ថែមទៅលើវណ្ណៈចាស់ទាំងបី ដែលធ្លាប់មានរួចមកហើយ ព្រមទាំងធ្វើការបែងចែកមុខងារទៅតាមវណ្ណៈនីមួយៗ ឱ្យបានច្បាស់លាស់ ។

- លើកទឹកចិត្ត និងផ្តល់ជូនចំពោះកសិករនូវមុខរបរថ្មី (អ្នកដែលពុំមានលទ្ធភាពប្រកបមុខរបរធ្វើស្រែចំការ ) ។

គួរកត់សំគាល់ថាមកទល់សព្វថ្ងៃនេះ គេប្រើឈ្មោះរបស់លោកសំរាប់សំគាល់ច្បាប់ដែលប្រកបដោយគតិបណ្ឌិត ។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោក គ្លីសធីនីស

## ៥៧០-៥០៧ មុនគ.ស

### ជីវិត និង គំនិតនយោបាយ



លោកត្រូវបានប្រជាពលរដ្ឋនៅអាតែនចាត់ទុកជាវីរបុរសពីព្រោះលោកបាននាំមកនូវលទ្ធិប្រជាធិបតេយ្យបញ្ចូលទៅក្នុង រដ្ឋាភិបាលដែលមុននេះត្រួតត្រាដោយពួកអប្បជនាធិបតេយ្យ ( រដ្ឋាភីបាលដឹកនាំដោយមនុស្សមួយក្រុមតូច ) ។

- ក្នុងឋានៈជាអ្នកតែងច្បាប់ លោកមានបំណងចង់កសាងឡើងវិញ នូវប្រព័ន្ធនយោបាយប្រជាធិបតេយ្យដ៏ពិតប្រាកដមួយសំរាប់ទីក្រុងអាតែន ។ កុលសម្ព័ន្ធចំនួនបួនដែលមានរួចមកហើយកាលពីពេលមុនត្រូវបានពង្រីកបន្ថែមរហូតដល់ ដប់កុលសម្ព័ន្ធ ។


www.elibraryofcambodia.org

- កុលសម្ព័ន្ធនិមួយៗត្រូវមានសមាជិកមកពីបូរីផង ស្រុកស្រែចំការផង និងពីឆ្នេរសមុទ្រផង ។

- ពង្រីករដ្ឋសភាដោយពង្រីកនូវអំណាចសភា និងបង្កើតក្រុមប្រឹក្សាថ្មីមួយ ដែលមានសមាជិក៥០០នាក់ ក្នុងនោះគឺ ៥០នាក់មកពីកុលសម្ព័ន្ធនីមួយៗ ។

- ក្រុមប្រឹក្សា (Council) ជាអ្នកគ្រប់គ្រង និង តែងច្បាប់ ហើយត្រូវបានយល់ព្រមដោយសភា ។

- មន្ត្រីរបស់រដ្ឋត្រូវជ្រើសរើសដោយប្រជាពលរដ្ឋ ។

- អំណាចប្រតិបត្តិត្រូវប្រគល់ទៅឱ្យ ឧត្តមសេនីយ៍ចំនួន១០រូប (Strategus) ដែលបោះឆ្នោតជ្រើសរើសក្នុង១ឆ្នាំម្តង ។

- ដើម្បីការពារកុំឱ្យមានរបប "មនុស្សម្នាក់ជាអ្នកដឹកនាំ" ( one-man rule ) ក្នុង១ឆ្នាំម្តង ពលរដ្ឋអាតែន អាចសរសេរអំពីឈ្មោះមនុស្សដែលគេយល់ឃើញថាគ្រោះថ្នាក់ ផ្ញើជូនចំពោះរដ្ឋាភិបាល ។ បើមានចំនួនរហូតដល់ ៦០០០សំឡេង បុគ្គលនោះត្រូវគេនិរទេសក្នុងរយៈពេល១០ឆ្នាំ ។

- រចនាសម្ព័ន្ធថ្មីនេះត្រូវឈរលើគោលការណ៍ "សិទ្ធិស្មើគ្នាចំពោះពលរដ្ឋគ្រប់រូប" ហើយនិងការចូលរួមដ៏ទូលំទូលាយក្នុងកិច្ចការ របស់រដ្ឋាភិបាល (Liberty-equality) ។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកប៉េរិគ្លីស(Pericles)

## ៤៩៥-៤២៩ មុនគ.ស

### ១-ជីវិត និង ស្នាដៃ




- លោកជាមគ្គុទ្ទេសក៍ ដ៏សំខាន់បំផុតរបស់អាតែន ក្នុងចន្លោះឆ្នាំ (៤៦១-៤២៩មុនគ.ស) ។

- ឪពុករបស់ លោកជាបញ្ជាការកងទ័ព ដែលធ្លាប់ទទួលជ័យជំនះលើពួក Perse នៅ Mycale ក្នុងឆ្នាំ៤៧៩មុនគ.ស ។



www.elibraryofcambodia.org

- លោកបានទទួលឥទ្ធិពលពីមនុស្ស ពីរនាក់ ដែលជាគ្រូរបស់លោក ៖ គឺលោកដាម៉ុង (Damon) ដែលជាសូហ្វីស (Sophist) និង លោកអាណាសាហ្គរ (Anaxagore) ដែលជាទស្សនវិទូផងដែរ ។ ក្នុងសម័យនោះ ទីក្រុងអាតែនទាំងមូលមានសន្តិភាព និង មានភាពរីកចំរើនរុងរឿង រហូតដល់គេដាក់ឈ្មោះថា "យុគសម័យមាសរបស់ ប៉េរីគ្លីស" ។

- លោកត្រូវបានមហាជនទទួលស្គាល់ថា ជាមនុស្សម្នាក់ដែលមានទេពកោសល្យ ខាងការនិយាយ និង ការសរសេរធ្វើឱ្យគេជឿ និងចូលចិត្តស្តាប់ មានសុខុមញ្ញាណ (Sagacity) និងមានស្មារតីស្នេហាជាតិដ៏មុះមុត ។

- លោកបានធ្វើឱ្យបូរីអាតែនទាំងមូលក្លាយជាបូរីមួយ ល្អបំផុត ព្រមទាំងជាមជ្ឈមណ្ឌលមួយ ដែលមានការរីកចំរើនខាងវិស័យសិល្បៈ ស្ថាបត្យកម្ម និង ចម្លាក់ ព្រមទាំងរចនាសម្ព័ន្ធដទៃទៀត ដែលជាហេតុ ធ្វើឱ្យបូរីដទៃទៀតមានការភ័យខ្លាច ហើយរកមធ្យោបាយដើម្បីផ្តួលរំលំបូរីនេះ ។

## ២-គំនិតនយោបាយរបស់លោកក្នុងការរៀបចំបូរីអាតែន

- ពលរដ្ឋទាំងអស់ត្រូវចូលរួមយ៉ាងសកម្ម ក្នុងរដ្ឋាភិបាលដោយ បង្កើតឱ្យមានជាការិយាល័យនយោបាយសំរាប់ប្រជាជន។


www.elibraryofcambodia.org

- ពលរដ្ឋត្រូវបង់ថ្លៃក្នុងការចូលបំរើរដ្ឋាភិបាល ហេតុដូច្នេះហើយបានជាក្រោយមកគឺមានតែពួកអ្នកមានប៉ុណ្ណោះ ទើបអាចមានមធ្យោបាយគ្រប់គ្រាន់សំរាប់បំរើកិច្ចការរបស់រដ្ឋាភិបាល ។

- សមាជិកក្រុមប្រឹក្សាទាំងអស់ ត្រូវបានជ្រើសរើសចេញពីប្រជាជនរបស់បូរីអាតែន ។

- អនុវត្ត នយោបាយ រាតទីនិយម ។

## ៣-ការត្រិះរិះពិចារណាទៅលើប្រជាធិបតេយ្យអាតែន

ប្រជាធិបតេយ្យនៅអាតែនត្រូវបានគេចាត់ទុកថាជា ប្រជាធិបតេយ្យ ដែលមានលក្ខណៈមិនគ្រប់គ្រាន់ ព្រមទាំងខុសប្លែកពីប្រជាធិបតេយ្យក្នុងពេលបច្ចុប្បន្ននេះទៀតផង ពីព្រោះថា :

- ពុំមែនអ្នកណាក៏ដោយ ក៏អាចក្លាយទៅជាប្រជាពលរដ្ឋរបស់អាតែនទាំងអស់នោះទេ ។ ក្នុងចំណោមមនុស្ស ៣០០.០០០នាក់នៅក្នុងទីក្រុងនេះ មាន ១៥០.០០០នាក់ជាទាសករ និង ជាជនបរទេស ដែលគ្មានសិទ្ធិខាងនយោបាយ ។

- បូរីអាតែន កម្រនឹង អនុញ្ញាតឱ្យជនបរទេសក្លាយទៅជាពលរដ្ឋ របស់បូរីនេះណាស់ ។ លោកប៉េរីគ្លីស អនុញ្ញាតឱ្យទៅជាពលរដ្ឋនៃបូរីនេះបាន លុះត្រាតែឪពុកម្តាយរបស់អ្នកទាំងនោះ ជា


www.elibraryofcambodia.org

"ពលរដ្ឋ" របស់បុរី ។

- ទ្រព្យសម្បត្តិភាគច្រើន និងអំណាចរបស់អាតែនឋិតនៅលើទាសករ ដែលជាអ្នកបំរើ កសិករ និងសិប្បករ ។

- ស្ត្រីមិនមានសិទ្ធិបោះឆ្នោត កាន់កាប់ការិយាល័យ ឬ ក៏សម្បត្តិ ទ្រព្យក្នុងអាតែនទេ ។ ស្ត្រីស្ទើរតែគ្មានសិទ្ធិទទួលការអប់រំ និង តួនាទីអ្វីសោះ នៅក្នុងសង្គម ។

- ពលរដ្ឋអាតែនអនុវត្តប្រជាធិបតេយ្យដោយផ្ទាល់ ។

- ដើម្បីរួមចំណែកក្នុងសភា ពលរដ្ឋម្នាក់ៗ អាចចូលរួមដោយខ្លួនឯង តែមិនអាចជ្រើសរើសអ្នកផ្សេងទៀតឱ្យចូលរួមជាមួយខ្លួនបានឡើយ ។ ក្នុងអណត្តិនីមួយៗ មានពលរដ្ឋអាតែនពី ៥០០០ ទៅ ៦០០០នាក់ ក្នុងសភា ។



www.elibraryofcambodia.org

# គំនិតនយោបាយក្នុងកំណត់ត្រារបស់លោកហេរ៉ូដូត

# (Hérodote)

## ៤៨០-៤២៥ មុនគ.ស

## ៤៨៥-៤២០ មុនគ.ស

## I.បុគ្គលិកលក្ខណៈ



- លោកត្រូវបានគេស្គាល់តាម រយៈការសរសេរប្រវត្តិសាស្ត្រ របស់លោក តាមរូបភាពជា កំណត់ត្រា ឬក៏ជា សេចក្តីរាយការណ៍ (Compte-rendu) ទៅលើ ព្រឹត្តិការណ៍ទាំងឡាយ ដែលកើតមានឡើង នៅក្នុងសម័យកាលរបស់លោក ។

- ដោយសារហេតុផលនេះរូបលោកត្រូវបានគេចាត់ទុកថាជាបិតានៃប្រវត្តិសាស្ត្រនិងជាបិតាខាងនយោបាយ ។ ពេលខ្លះគេក៏ចាត់ទុករូបលោក ជាបិតានៃប្រជាធិបតេយ្យថែមទៀតផង ។



www.elibraryofcambodia.org

## II. ប្រភពនៃគំនិតនយោបាយតាមរយៈការកត់ត្រារបស់លោក

លោកបានកត់ត្រាអំពីដំណើរនៃការរៀបចំបូរី បន្ទាប់ពីការបះបោរទទួលបានជ័យជំនះ ។ តាមរយៈការកត់ត្រានេះ គេបានដឹងថាមេដឹកនាំ ការបះបោរនោះឈ្មោះ ស្មែរឌីស ហើយបានស្លាប់នៅពេលកំពុងដឹកនាំ ការប្រយុទ្ធ ។

បន្ទាប់ពីទទួលបានជ័យជំនះ ក្រុមរបស់លោកនៅសល់គ្នាតែប្រាំពីរនាក់ប៉ុណ្ណោះ ។ ក្រុមនោះបានជួបប្រជុំគ្នា រិះរកនូវគំនិតសំខាន់ៗ ដើម្បីដឹកនាំនិងគ្រប់គ្រងបូរីតទៅមុខ ។

គួរកត់សំគាល់ដែរថា ក្នុងចំណោមអ្នកទាំងប្រាំពីរមានតែបីនាក់ប៉ុណ្ណោះដែលបានលើកឡើងនូវគំនិតរបស់ខ្លួន ។

### ១-លោកអូតាណែស

លោកបានឱ្យយោបល់ចំពោះអង្គប្រជុំថា ដើម្បីគ្រប់គ្រងបូរីឱ្យបានល្អកុំឱ្យឈ្លោះប្រកែកគ្នា នោះគួរតែប្រជាជនជាអ្នកសំរេចជោគវាសនារបស់គេ បានន័យថាត្រូវស្គាល់មតិរបស់ប្រជាជន ។ គាត់មិនពេញចិត្តទៅលើរបបគ្រប់គ្រងមួយ ដែលប្រគល់ជោគវាសនារបស់បូរីទៅលើបុគ្គលតែម្នាក់នោះឡើយ ។

ឆ្លងតាមគំនិតរបស់លោក អូតាណែស លោក មានគំនិតចង់រៀបចំ ប្រទេសតាមបែបប្រជាធិបតេយ្យ ។



www.elibraryofcambodia.org

## ២-លោកម៉េហ្គាប៊ីស

លោកយល់ស្របតាមលោក អូតាណែសដែរ ប៉ុន្តែគាត់មានគំនិតថ្មីមួយទៀតថា បើប្រជាជនគ្រប់គ្រងទាំងអស់នោះ បូរីអាចនឹងគ្មាន មេកោយហើយសង្គមអាចក្លាយទៅជាអាណាធិបតេយ្យ ។ គាត់ថា ត្រូវមានអ្នកចេះមួយក្រុម ដើម្បីទទួលបន្ទុកគ្រប់គ្រង ។

ឆ្លងតាមគំនិតនេះលោកម៉េហ្គាប៊ីស ចង់រៀបចំប្រទេសតាមបែប អភិជនាធិបតេយ្យ ។

## ៣-លោកដារីយូស

លោកបានឱ្យយោបល់ប្លែកពីគេ លោកគិតថា បូរីត្រូវមានមនុស្សម្នាក់ជាអ្នកគ្រប់គ្រង ។ មនុស្សក្នុងបូរីទាំងអស់ត្រូវស្តាប់បង្គាប់ មនុស្សម្នាក់នោះ ។

ឆ្លងតាមគំនិតនេះ លោក ដារីយូស ចង់រៀបចំប្រទេសទៅតាម របបរាជាធិបតេយ្យ ។

ជជែកគ្នាមិនដាច់ស្រេច អ្នកទាំងប្រាំពីររូបបែកគំនិតថាត្រូវធ្វើការបោះឆ្នោត ។ ប៉ុន្តែពេលនោះលោកដារីយូស សុំដកខ្លួនចេញព្រោះ រូបលោកមាននិន្នាការធ្ងន់ ទៅលើរបបរាជាធិបតេយ្យ ។ លោកសុំឱ្យ អ្នកទាំងប្រាំមួយបោះឆ្នោតចុះ លោកសុំដកខ្លួនថយ



www.elibraryofcambodia.org

ហើយលោកសំណូមពរ កុំឱ្យអ្នកទាំងប្រាំមួយរូប ទៀតតាមទៅសង្កត់សង្កិនរូបគាត់ទៅថ្ងៃក្រោយ ។ ទោះជាយ៉ាងនេះក្តី គាត់នៅតែគិតថា គំនិតរបស់លោកអ្នូតាណែស អាចល្អជាងគេហើយធ្វើឱ្យបូរីមានការរីកចំរើនទៅអនាគត ។

នេះជាទ្រង់ទ្រាយនៃគំនិតនយោបាយក្នុងការរៀបចំបូរីរបស់ប្រទេសក្រិកបូរាណតាមការកត់ត្រារបស់លោក ហេរ៉ូដូត ។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកអ៊ីប៉ូដាមដឺមីឡេ

# (Hippodame de Millet)

## I .ប្រវត្តិសង្ខេប

- លោកត្រូវបានគេទទួលស្គាល់ថា ជាអ្នករៀបចំរចនាសម្ព័ន្ធនយោបាយ របស់បុរី(Urbaniste politique) ។

- គេមិនបានដឹងច្បាស់ពីឆ្នាំដែលលោកកើតនោះទេប៉ុន្តែគេគ្រាន់តែដឹងថា លោកជាវរជនដ៏ល្បីល្បាញ ក្នុងសតវត្សរ៍ទី៥មុនគ.ស ដែលបានរួមសហការរៀបចំបុរី ជាមួយលោកប៉េរីគ្លីស (Pericles)

- គេស្គាល់រូបលោកតាមការពិណ៌នា និងការរិះគន់របស់លោកអារីស្តូត តែប៉ុណ្ណោះ ។

- លោកជាជនបរទេស មិនមែនជាពលរដ្ឋរបស់បុរីអាតែនទេ ។

## II .គំនិតនយោបាយសំខាន់ៗ

លោកបានផ្តល់គំនិត ដើម្បីរៀបចំបុរីមួយឱ្យបានល្អឥតខ្ចោះ (Cité Ideale) ជាបុរីក្នុងពិភពគំនិត ឬ មនោបុរី ។ ដើម្បីសំរេចគោលដៅនេះ បុរីត្រូវមានប្រជាពលរដ្ឋចំនួន១០០០០នាក់ ហើយអ្វីៗទាំងអស់ ត្រូវបែងចែកជាបី (វណ្ណៈ_ដីធ្លី_ទាហាន) ។



www.elibraryofcambodia.org

## ១-តាមវណ្ណៈ

ពលរដ្ឋរបស់បូរីត្រូវចែកចេញជាវណ្ណៈបី ដាច់ដោយឡែកពីគ្នា ៖

- ពួកវរជន (Elite : ជាអ្នកទទួលបន្ទុក ថែរក្សាការពារផលប្រយោជន៍រួមរបស់បូរី ជាអ្នកបង្កើតនូវបទបញ្ញា សេចក្ដីសំរេចនានា និងជាអ្នករៀបចំការងាររបស់បូរី ។

- ពួកជនដែលមានកាយសម្បទាមាំមួន (Homme robuste) ជាអ្នកដែលទទួលបន្ទុកការពារបូរី (ពួកទាហាន) ។

- ពួកជនឧស្សាហ៍ព្យាយាម(Les Laborieux) ជាអ្នកផលិតនូវ ភោគទ្រព្យសំរាប់បូរី ។

## ២-តាមប្រជាជន

ប្រជាជនត្រូវបែងចែកជាបីដូចខាងលើដែរ ប៉ុន្តែវណ្ណៈនីមួយៗត្រូវ បែងចែកជាបីក្រុម ៖ ពួកវរជនត្រូវចែកជាគណៈកម្មាធិការរៀបចំនូវបទបញ្ញា និងសេចក្ដីសំរេចនានា ។ សេណា (sénat) ជាអ្នកធ្វើច្បាប់និងជាអ្នកដំណាងរាស្ត្រ ហើយនិងអាជ្ញាធរប្រតិបត្តិផង (Autorité exécutive) ។ ចំពោះទាហាន ក៏បែងចែកជាបីដែរ គឺ អគ្គសេនាធិការ (Etat-Major) កងអន្តរាគមន៍ (Corps d'intervention) កងទ័ពជាតិប្រដាប់អាវុធ ( Nation armée ) ដែលជាអ្នក ការពារបូរី និងផ្ដល់កងទ័ពក្នុងពេលបូរីមានសង្គ្រាម ។



www.elibraryofcambodia.org

ចំពោះជនឧស្សាហ៍ព្យាយាម ក៏ត្រូវចែកជាបីដែរ គឺ ៖ កសិករ សិប្បករ និងពាណិជ្ជករ ។ រីឯដីធ្លីវិញ ក៏បែងចែកជាបីប្រភេទដែរ គឺ ដីសាធារណៈ ដីពិសិដ្ឋ (Terre sacrée) និង ដីឯកជន (Terre privée) ។

## ៣-សិទ្ធិរបស់វណ្ណៈ

វណ្ណៈនីមួយៗ គ្មានសិទ្ធិទាមទារនូវអំណាចផ្ដាច់មុខឡើយ ។ ពួកគេជាសមាជិករបស់បូរី ព្រមទាំងអាចទទួលយកនូវទីតាំងផ្សេងទៀតក្រៅពីវណ្ណៈរបស់ខ្លួន ។ លោកត្រៀមរៀបចំ ឱ្យមានជាការបោះឆ្នោត ។

## ៤-ការរៀបចំបូរី

ការរៀបចំបូរីត្រូវអនុវត្តទៅតាមស្ថាបត្យកម្មមួយឯកភាព ។ ត្រូវមានផ្លូវ មានផ្ទះសង់ជាជួរ មានសណ្ដាប់ធ្នាប់ ដើម្បីងាយស្រួលគ្រប់គ្រងការពារ និងធ្វើសេដ្ឋកិច្ច ។

## ៥-របបគ្រប់គ្រងបូរី

លោកស្នើឱ្យមានរបបគ្រប់គ្រងចំរុះ ដោយបដិសេធចោលនូវរបបអប្បជនាធិបតេយ្យ (Oligarchie ) និង ប្រជាហិង្សា (Tyrannie) ។ លោកមិនស្រឡាញ់របបរាជាធិបតេយ្យទេព្រោះ



www.elibraryofcambodia.org

លោកយល់ថា ជារបបមួយដែលគ្រាប់តាមបញ្ញារបស់ អាទិទេព ស្រឡាញ់ ភាពប្រណិត និងព្រហើនកោងកាច ។

## ៦-ការការពារបូរី

- បូរីតែងតែទទួលការគំរាមគំហែងពីខាងក្នុងផង និងពីខាងក្រៅ ផង ។ គ្រោះថ្នាក់ខាងក្រៅគឺបណ្ដាលមកពីជាតិសាសន៍ដទៃ (ក្រៅ ប្រទេស និងក្នុងប្រទេស) ។ គ្រោះថ្នាក់ខាងក្នុង គឺបណ្ដាលមកពី ការបះបោរ និងការបែងចែកជាបក្សពួក (Faction) ។

- ត្រូវបណ្ដុះបណ្ដាលយុវជនឱ្យស្គាល់ ពីធាតុពិតនៃការលំបាក និងមិនភ្លើតភ្លើនឆ្ពោះទៅរកសេចក្ដីសប្បាយដោយឥតព្រំដែន និងអបាយមុខ ។ ត្រូវចេះរក្សានូវប្រពៃណីទំនៀមទំលាប់របស់ជាតិ ។

- ថែរក្សានូវធនធានរបស់ជាតិ ។

- រក្សានូវសមភាពធនធានរបស់បុគ្គល ព្រមទាំងទប់ស្កាត់នូវវិសមភាពហួសហេតុដែលបង្កឡើងអំពីធនធាន ។

- រក្សានូវលំនឹងរបស់បូរី ដែលជាបន្ទុកទទួលខុសត្រូវរបស់អ្នកដែលមានសមត្ថភាព ។

- ត្រូវផ្ដល់នូវកិត្តិយស ចំពោះតុលាការ ដែលបានបំពេញការងាររបស់ខ្លួនបានល្អព្រមទាំងរក្សាបាននូវភាពថ្លៃថ្នូរក្នុងការងារដែល ប្រគល់ឱ្យ ។



www.elibraryofcambodia.org

- ប្រើប្រាស់នូវការប្រកួតប្រជែង ដើម្បីផ្លាស់ប្តូរអំណាច ពីម្នាក់ ទៅម្នាក់ ។

- ប្រជាធិបតេយ្យ គឺជាកិត្តិយស ចាំបាច់ត្រូវធ្វើឱ្យពលរដ្ឋម្នាក់ៗក្លាយទៅជាសមាជិករបស់បូរី ។

## ៧-ការថែរក្សាបូរី

ដើម្បីថែរក្សាបូរីមួយបាន គេត្រូវមានទ្រឹស្តី និងជំនឿ ។ ទន្ទឹមនឹងនោះត្រូវមានចំណូលចិត្តទំនៀមទំលាប់ព្រមទាំងរៀបចំបូរីនោះឱ្យមានជាច្បាប់ទំលាប់ត្រឹមត្រូវ ។ ទ្រឹស្តី និង ជំនឿ អាចកែលំអមនុស្ស ឱ្យប្រាសចាកពីតណ្ហា ។ ត្រូវរក្សាឱ្យមានលំនឹង រវាងចំណង់ចំណូលចិត្ត និង ទំនៀមទំលាប់ ។ ច្បាប់ទំលាប់ អាចធ្វើឱ្យមនុស្សចៀសវាង បានពីអំពើអាក្រក់ ។

ជំនឿ ទំនៀមទំលាប់ និង ច្បាប់ ជាកម្មវត្ថុបីសំខាន់ ពោលគឺធ្វើឱ្យមនុស្សសំរេចបាននូវគុណធម៌ យុត្តិធម៌ និងសារប្រយោជន៍ ។

លោកអ៊ីប៉ូដាម ដឺមីឡេ មិនទុកចិត្តចំពោះពួក សូហ្វិស ឡើយពីព្រោះ លោកបានមើលឃើញថា ពួកគេតែងតែសាបព្រួសនូវការសង្ស័យ ជានិច្ចក្នុងស្មារតីរបស់ប្រជាពលរដ្ឋ ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកសេណូហ្វុង(Xénophon)

## ៤៣០_៣៥៥ មុនគ.ស

### I. ជីវិតនិងបុគ្គលិកលក្ខណៈ



- លោកកើតនៅ អាតែន ក្នុងកុលសម្ព័ន្ធឈ្មោះណាយ ដែលជាអ្នកថែសេះចំបាំង ។

- លោកជាកូនសិស្ស របស់សូក្រាត ។

- លោកស្រឡាញ់ ការគ្រប់គ្រងរបស់ប៉ូវី ស្ប៉ាត ។

- លោកត្រូវបាន គេទទួលស្គាល់ថា ជាប្រវត្តិវិទូ ក្រិក និង ជាទាហានដ៏អង់អាចក្លាហាន និងជាអ្នកនិពន្ធដ៏ល្បីល្បាញ ។ កូនាទីរបស់លោក បានរួមវិភាគទានដ៏ធំធេង ទៅលើចំណេះដឹងទាំងឡាយ ស្តីពីចក្រភពក្រិក និង ប៉ូវីស្ប៉ាតក្នុងស.ត ទី៤មុនគ.ស។

- លោកបាននិពន្ធស្នាដៃជាច្រើន សំខាន់គឺស្នាដៃដែលមានឈ្មោះថា Les Mémorables និង Anabasis ។



www.elibraryofcambodia.org

- លោកជាអ្នកធ្វើដំណើរផ្សងព្រេងមួយរូប ។

- លោកជាទាហានស៊ីឈ្នួលចំបាំងរបស់ប៉ូរីអាតែនក្នុងឆ្នាំ៤០១ មុនគ.ស ក្នុងករណីដែលព្រះអង្គម្ចាស់ស៊ីរូស ច្បាំងគ្នាជាមួយបងប្រុស បង្កើតរបស់ខ្លួនគឺព្រះអង្គម្ចាស់ អាតាក់សែរស្សេទី II ។ ក្រោយពេល ដែលព្រះអង្គម្ចាស់ស៊ីរូស សុគតទៅ ហើយគាប់ជួនពេលដែល មេបញ្ជាការកងទ័ពត្រូវបានពួកពែរស៍ធ្វើឃាតផងនោះ រូបលោក ត្រូវបានគេ ជ្រើសរើសឱ្យទទួលបន្ទុក ជាមេបញ្ជាការដឹកនាំទ័ព ចំនួន១០.០០០នាក់ ដើម្បីត្រឡប់មកអាតែនវិញដោយធ្វើដំណើរថ្មើរ ជើងក្នុងរយៈចម្ងាយ ២៤១៤គ.ម (១៥០០ម៉ាយ) លើទឹកដីពែរស៍ (អាស៊ីមីនើ) ប្រកបដោយគ្រោះថ្នាក់ និងទីកន្លែងផ្សេងៗ ទៀតដែលពុំធ្លាប់ស្គាល់។ លោកបាននាំទ័ពឆ្លងកាត់សមុទ្រ និង អាកាសធាតុ ដ៏អាក្រក់នៃវាលខ្សាច់ ព្រមទាំងក្រខ្សត់ដោយខ្វះស្បៀងអាហារក្នុង រយៈពេល៥ខែ ។ លោកបានគូសបញ្ជាក់ពី ព្រឹត្តិការណ៍អស់ទាំងនេះ នៅក្នុងស្នាដៃរបស់លោក ឈ្មោះថា អាណាបាស៊ីស ។

- លោកជាមនុស្សម្នាក់ ដែលមានលក្ខណៈស្និទ្ធស្នាល និងសាមញ្ញ ហើយត្រូវបានមនុស្សក្នុងក្រុមចាត់ទុកថាជាជនគំរូម្នាក់ប្រកបដោយ ភាពឈ្លៀសវៃ និង ប៉ិនប្រសប់ ។


www.elibraryofcambodia.org

## II. គំនិតនយោបាយសំខាន់ៗ

### ១-ទិទៀនប្រជាធិបតេយ្យរបស់លោកប៉េរី គ្លីស

លោកបានធ្វើការទិទៀនគំនិតនយោបាយស្តីពី ប្រជាធិបតេយ្យ របស់លោកប៉េរីគ្លីសតាមរយៈវណ្ណកម្មរបស់លោកឈ្មោះម៉េម្ម៉ូរ៉ាប្លូ។ ក្នុងការទិទៀននោះ លោកបានបង្កើតតួអង្គពីរនាក់ឱ្យជជែកគ្នា គឺ ឈ្មោះ អាល់ស៊ីប៊ីយ៉ាត និង ប៉េរីគ្លីស អំពីបញ្ហាប្រជាធិបតេយ្យ ប៉ុន្តែលោកមិន ធ្វើការសន្និដ្ឋានទេ ។

លោកបានលើកឡើងថាបញ្ហា"ចំនួន" មិនមានលក្ខណៈគ្រប់គ្រាន់ឡើយ ដើម្បីបង្កើតនូវ "ភាពត្រឹមត្រូវ" ។ លោកបាន លើកជាសំណួរថាតើ "ចំនួនច្រើន" អាចចាប់បង្ខំតាមលក្ខណៈច្បាប់ទៅលើពួកអ្នកមានដោយគ្មានការយល់ព្រមពីសំណាក់ពួកទាំងនោះបានដែរ ឬទេ ? តាមយោបល់របស់លោក លោកថាមិនអាចធ្វើទៅបានឡើយគឺ មានតែប្រើអំពើហឹង្សាទេទើបអាចដោះស្រាយបាន ។

សិទ្ធិនៃការនិយាយស្តី : តាមគំនិតរបស់លោក សិទ្ធិនៃការនិយាយស្តី ដែលត្រូវបានយល់ព្រមផ្តល់ចំពោះ មនុស្សទាំងអស់មានទាំង អ្នកល្ងង់ខ្លៅផង នោះគឺមិនត្រឹមត្រូវទេ ។ សិទ្ធិនៃការធ្វើអ្វីទៅតាម អំពើចិត្តដែលត្រូវចាត់ទុកថា ជាដំណាងឱ្យសេរីភាព


www.elibraryofcambodia.org

របស់បុគ្គល ម្នាក់ៗ នោះគឺជាគ្រោះថ្នាក់ធំបំផុត ។ បទបញ្ញា និង ច្បាប់ គឺជាអំណាចផ្តាច់ការរបស់មេ ឬវិរបុរស ហើយជាឱសថមួយ សំរាប់រក្សាលំនឹង របស់ប្ញី ។

## ២-នយោបាយ

នយោបាយគឺជាសិល្បៈធំជាងគេបង្អស់ ។ អំណាចខាងសិល្បៈ នយោបាយ គឺជាគំនិតដ៏ខ្ពស់បំផុត ដែលម្នាក់ៗ អាចឈោងចាប់បាន ។ ចំណេះដឹងខាងនយោបាយ បានធ្វើឱ្យមនុស្សម្នាក់ៗ ក្លាយទៅជា អ្នកប្រកបដោយគុណធម៌ មានភាពទៀងត្រង់ ប៉ុន្តែភាពល្ងង់ខ្លៅក្នុងបញ្ហានយោបាយ បានធ្វើឱ្យមនុស្សម្នាក់ៗ ថោកទាបរហូតដល់ថ្នាក់ជាទាសករ ។

## ៣-មេ

តាមគំនិតរបស់លោក អ្នកដែលអាចក្លាយទៅជា "មេ" បានត្រូវមានលក្ខណៈវិនិច្ឆ័យ៧យ៉ាងគឺ :

**ទី១:** "មេ" ជាមនុស្សដែលចេះនយោបាយច្បាស់លាស់ និងមាន កិរិតនយោបាយខ្ពស់ជាងគេ ជាមនុស្សប្រកបដោយ គុណធម៌ និងមាន ភាពទៀងត្រង់ ។


www.elibraryofcambodia.org

**ទី២:** អ្នកដឹកនាំគ្រប់គ្រងមិនមែនសុទ្ធតែមានលក្ខណៈជាមេទាំងអស់នោះទេ ។ **"មេ"** មិនមែនជាអ្នកដែលកាន់ដំបងព្រនង់សំឡុត គំរាម ឱ្យគេភ័យ ហើយត្រូវបាន ហ្វូងមនុស្សជ្រើសរើសនោះទេ ហើយក៏មិនមែនជាអ្នកដែល ត្រូវបានគេតែងតាំងដោយចាប់ឆ្នោត នោះដែរ។ សរុបមក **"មេ"** គឺជាអ្នកដែលចេះបញ្ជា ។

**ទី៣:** **"មេ"** គឺជាមនុស្សដែលគេទាំងអស់គ្នាទទួលស្គាល់ថាជា អ្នកដែលខ្ពង់ខ្ពស់គួរឱ្យគោរព ។

**ទី៤:** **"មេ"** ជាអ្នកដែលប៉ិនប្រសប់ខាងពាក្យសំដី និយាយបញ្ចុះ បញ្ចូល និងចេះធ្វើឱ្យគេជឿជាក់ ។

**ទី៥:** **"មេ"** គឺជាអ្នកដែលចេះគិតគូរ ពីផលប្រយោជន៍រួមបំរើ ផលប្រយោជន៍រួម និង ជួយការពារផលប្រយោជន៍ របស់មនុស្សដែល នៅក្រោមបង្គាប់របស់ខ្លួន ។

**ទី៦:** **"មេ"** គឺជាមនុស្សដែលមានគុណធម៌ ជំនះបាននូវសភាវៈគតិ និង តណ្ហាទាំងឡាយរបស់ខ្លួន ។

**ទី៧:** **"មេ"**គឺជាអ្នកដែលមិនប្រើអំណាចចាប់បង្ខំទៅលើអ្នកដែលនៅក្រោមបង្គាប់មានន័យថា ត្រូវធ្វើយ៉ាងណាឱ្យអ្នកនៅក្រោម បង្គាប់ធ្វើតាមប្រកបដោយក្តីគោរព ។



www.elibraryofcambodia.org

## ៤-រាជានិយមផ្តាច់ការនិងអំណាចផ្តាច់ការ(ប្រជាធិបតេយ្យ)

លោកចូលចិត្តរដ្ឋាភិបាលមួយ ដែលមានសារជាតិជាទាហាន ផ្តាច់ការជាងរាជានិយម ។ លោក បានផ្តល់ទស្សនៈរបស់លោក ដោយយកឧទាហរណ៍ទៅលើអំណាចពីរបែប ដែលធ្លាប់មានរួចមកហើយ គឺអំណាចតាមបែបរាជានិយមរបស់ ម៉ែដ និង អំណាចតាមបែបរាជា និយមរបស់ពែរស៍ ។

- **រាជានិយមរបស់ម៉ែដ :** ជារាជានិយមផ្តាច់ការ ខ្ពស់បំផុត ដឹកនាំគ្រប់គ្រងបូរីទៅតាមគំនិតរវើរវាយរបស់បុគ្គល ឃ្លាតចាកពីច្បាប់របស់បូរីដែលបានចែង ។

- **រាជានិយមរបស់ពែរស៍ :** ជារបបរាជានិយមដែលប្រើប្រាស់អំណាចត្រឹមត្រូវ ពោលគឺជា រាជានិយម ដែលមានលក្ខណៈត្រឹមត្រូវ ។ ស្តេចមិតនៅជាជនផ្តាច់ការ ប៉ុន្តែទទួលនូវការអប់រំអំពី "អំណាច" បានល្អ មានយុត្តិធម៌ និងបំរើផលប្រយោជន៍របស់រដ្ឋ ។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកប្លាតុង(Platon)

## ៤២៧-៣៤៧ មុនគ.ស

## I.ជីវិត



- លោកកើតនៅក្នុង ត្រកូលអភិជន នៃបុរីអាតែន ។ ឯកសារខ្លះបានបញ្ជាក់ថា លោកកើតនៅអីហ្សិន(Egine) ។ ឈ្មោះប្លាតុងបើតាមភាសាក្រិកមានន័យថា "ធំសំបើម" ស្របទៅតាមរាងកាយរបស់គាត់ ដែលមានមាឌធំ ។ ឈ្មោះពិតប្រាកដរបស់លោក គឺ Aristoclès ។



www.elibraryofcambodia.org

- ឪពុករបស់លោកឈ្មោះ Ariston ដែលជាប់ត្រកូលជាមួយរាជវង្សនៅអាតែន ។

- ម្តាយរបស់លោក ឈ្មោះនាង ប៉េរីស្សៀន ( Périctione ) ដែល ជាប់ខ្សែស្រឡាយជាមួយអ្នកតែងច្បាប់ឈ្មោះ លោកសូឡុង (Solon) ។

- តាំងពីក្មេងមក លោកបានរៀនទូវចំណេះវិជ្ជាជាច្រើនដូចជា កំណាព្យ អក្សរសាស្ត្រ ល្ខោន វិចិត្រកម្ម ដូរ្យតន្ត្រី ការហាត់ប្រាណ និងគណិតវិទ្យា ។

- លោកកំព្រាឪពុកតាំងពីនៅកុមារមកម៉្លេះ ។ ពេលដែលឪពុកស្លាប់ទៅ ម្តាយរបស់លោក បានរៀបការជាមួយលោក ពីរឡេម (Pyrilampes) ដែលជាអ្នករួមសហការជាមួយរដ្ឋបុរសឈ្មោះ ប៉េរីគ្លីស (Pericles) ។

- ការចាប់កំណើតរបស់លោក បានផ្សារភ្ជាប់ទៅនឹងការស្លាប់របស់លោក ប៉េរីគ្លីស ដែលជាមគ្គុទ្ទេសក៏ ប្រជាធិបតេយ្យដ៏ធំបំផុតរបស់បូរីអាតែន ព្រមទាំងជាមួយការចាប់ផ្តើម នៃសង្គ្រាមរវាង បូរីស្ប៉ាត និង បូរីអាតែន នៅប៉េឡូប៉ូណែស (៤៣១-៤០៤) ហើយ សង្គ្រាមនេះ បានបន្តរហូតដល់លោក មានអាយុ២៣ឆ្នាំ ទើបបូរីអាតែន ចុះចាញ់បូរីស្ប៉ាត ក្នុងឆ្នាំ៤០៤ ។


www.elibraryofcambodia.org

- លោកមានមហិច្ឆិតាខាងនយោបាយ ។ លោកតែងតែទទួលនូវ ការមិនពេញចិត្ត ពីអ្នកដឹកនាំរបស់បូរីអាតែន ។

- គ្រូដើមរបស់លោក ឈ្មោះ ក្រាទីល (Cratile) ដែលជាទស្សនវិទូផ្នែក Sophiste ( ទស្សនវិទូដែលមានឯកទេសខាងការស្រាវជ្រាវ សិល្បៈវោហារសិល្បៈវែកញែក និង សិល្បៈគូសបញ្ជាក់ឱ្យ បានច្បាស់លាស់ ) ។ ប៉ុន្តែចាប់ពីលោក មានអាយុ២០ឆ្នាំមក លោកបាន ក្លាយជាសាវ័ក (កូនសិស្ស) របស់សូក្រាតវិញ ។ លោកបានទទួលយកទស្សនវិជ្ជាមូលដ្ឋាន និង វិចារវិទ្យា ផ្នែកពិភាក្សាតទល់គ្នា (ជជែកវែកញែក) (Debate) ។ គឺជាការដេញដោល រកការពិត តាមរយៈសំណួរចម្លើយ និងសំណួរបន្ថែម ដើម្បីឱ្យ គូសន្ទនា ទទួលស្គាល់ពីការខ្វះចន្លោះរបស់ខ្លួនលើផ្នែកចំណេះដឹង ។

- ភាពឆ្លាតវៃរបស់លោក បានធ្វើឱ្យ សូក្រាត (៤៦៩_៣៩៩) ពេញចិត្ត ហើយមានបំណង លើកលោកឱ្យធ្វើជា អ្នកបន្តវេន។ ជាចៃដន្យ ពេលនោះលោកសូក្រាត ត្រូវបានអាជ្ញាធរកាត់ទោសប្រហារជីវិត ដោយផឹកថ្នាំពុល ពីបទចោទប្រកាន់ថា បានពង្វក់សតិអារម្មណ៍ យុវជនឱ្យប្រឆាំងនឹងច្បាប់របស់បូរីអាតែន តាមរយៈការបង្ហាត់បង្រៀន របស់លោក ។ ក្រោយពេលលោកសូក្រាតស្លាប់ទៅអាស្រ័យ ដោយហេតុផលសន្តិសុខផ្ទាល់ខ្លួន លោកបាន


www.elibraryofcambodia.org

ចាកចេញពីបូរីអាតែន ទៅរស់នៅឯបរទេស ក្នុងរយៈពេល១២ឆ្នាំ ដូចជានៅប្រទេសអេហ្ស៊ីប អ៊ីតាលី និងកោះស៊ីស៊ីល ត្រង់ទីក្រុងមួយឈ្មោះ ស៊ីរ៉ាគុយ ។

- នៅភាគខាងត្បូងប្រទេសអ៊ីតាលី លោកបានទៅរស់នៅក្នុងដំបន់មួយឈ្មោះ ម៉េហ្គា លោកបានជួបនឹង មិត្តជិតស្និទ្ធរបស់លោកឈ្មោះ ឌីយ៉ុង(Dion) ដែលត្រូវជាបងថ្លៃរបស់ព្រះអង្គម្ចាស់ដេនីស I ( Denys I ) ។ ឌីយ៉ុង បានហៅលោកឱ្យទៅ ធ្វើជាទីប្រឹក្សារបស់ ដេនីស I ។ អ្នកទាំងពីរ បានរួមគំនិតគ្នា រាំងខ្ទប់នយោបាយផ្តាច់ការ របស់ដេនីស I ដែលជាហេតុធ្វើឱ្យព្រះអង្គម្ចាស់ខ្ញាល់ ព្រមទាំងមិន ទុកចិត្តចំពោះរូបលោក ។ ដេនីស I ដែលជាជនផ្តាច់ការ បានចាប់រូបលោក ប្រគល់ឱ្យបញ្ជាការរបស់ពួកនាវាស្ប៉ាត ។ គេបានលក់រូបលោក ឱ្យទៅម្ចាស់ទាសករ ប៉ុន្តែជាភ័ព្វសំណាង លោកត្រូវបានអ្នកដែល លោកធ្លាប់ស្គាល់ម្នាក់ឈ្មោះ Annichéris សង្គ្រោះឱ្យផុតពីភាពជា ទាសករ ហើយបញ្ជូនរូបលោកមក បូរីអាតែន វិញ ។

ក្នុងឆ្នាំ៣៨៧មុនគ.ស លោកប្លាតុង បានបង្កើតសាលាមួយឈ្មោះថា អាកាដេមី គឺជាស្ថាប័នមួយដែលត្រូវបានចាត់ទុកដូចជាសាកលវិទ្យាល័យទីមួយ សំរាប់ទ្វីបអឺរ៉ុប ។ សាកលវិទ្យាល័យនេះ


www.elibraryofcambodia.org

បានបង្រៀន មុខវិជ្ជាជាច្រើន ដូចជា តារាសាស្ត្រ ជីវវិទ្យា គណិតវិទ្យា ទ្រឹស្តីនយោបាយ ទស្សនវិជ្ជា ដែលនៅទីនោះ លោកអារីស្តូត បានរៀនសូត្រ ហើយបានក្លាយទៅជាសិស្សម្នាក់ ដែលគេទទួលស្គាល់ខាង សមត្ថភាព ។

- ឆ្នាំ៣៦៧ ដេនីស I ចូលទីវង្គត ដេនីស II ត្រូវជាកូន បានឡើងសោយរាជ្យបន្ត ។ លោកប្លាតុងត្រូវបានអញ្ជើញទៅ ស៊ីរ៉ាគុយម្តងទៀត ដើម្បីជួយបង្ហាត់បង្រៀន ដេនីស II លើផ្នែកទស្សនវិជ្ជា ។ ចំណេះដឹងទស្សនវិជ្ជានៅពេលនោះ មានឥទ្ធិពល គ្របដណ្តប់ទៅលើ ទីក្រុងទាំងមូល ។ ដេនីស II ក៏ដូចជា ដេនីស I តែងមានការសង្ស័យ និងមិនពេញចិត្តចំពោះរូបលោក និងឌីយ៉ុង ដែលត្រូវជាឪពុកធំ ស្របពេលដែលឌីយ៉ុង មានគំនិតចង់ឡើងសោយរាជ្យជំនួសក្មួយ ។ ឌីយ៉ុង និង ប្លាតុង ក៏មិនពេញចិត្តនឹងនយោបាយផ្តាច់ការ របស់ដេនីស II ដែរ ហើយតែងតែរិះរកនូវមធ្យោបាយ ដើម្បីក្បត់ព្រះអង្គ ។ ដោយសារតែរឿងនេះហើយ ឌីយ៉ុង ត្រូវនិរទេស ហើយប្លាតុងត្រូវបង្ខំចិត្តត្រឡប់មកអាតែន វិញ ដោយមិនរង់ចាំឱ្យ ដេនីស II ចាប់រូបលោកយកទៅលក់ ដូចមុនទៀតឡើយ ។

- ឆ្នាំ៣៦១ ប្លាតុងត្រូវបាន ដេនីស II អញ្ជើញឱ្យត្រឡប់ទៅវិញ


www.elibraryofcambodia.org

ម្តងទៀត ដើម្បីជួយក្នុងការបង្កើតសហព័ន្ធបូរីក្រិក ដើម្បីប្រឆាំងនឹង ការគំរាមកំហែងពីខាងក្រៅ ។ ក្នុងពេលស្នាក់អាស្រ័យនៅទីនោះ លោកបានជួយសំរុះសំរួលទំនាក់ទំនងរវាង ដេនីស II និងឌីយ៉ុង ។ ប៉ុន្តែ ជាការឥតប្រយោជន៍ កាយវិការរបស់លោកបែរទៅជាជួយឱ្យមានការ ដាក់ទោស កាន់តែធ្ងន់ធ្ងរលើរូបលោកឌីយ៉ុង ទៅវិញ ។ ដេនីស II បានបញ្ជាឱ្យរឹបអូសយកទ្រព្យសម្បត្តិរបស់ឌីយ៉ុង ព្រមទាំងបង្ខំឱ្យប្រពន្ធរបស់ឌីយ៉ុង រៀបការប្តីថ្មីទៀត។ ចំណែកលោក ប្លាតុង ដោយពុំបានទទួលជោគជ័យ ក្នុងការបង្កើតសហព័ន្ធបន្ថែមទៅលើកាយវិការរបស់ ដេនីស ចំពោះឌីយ៉ុង លោកក៏បានត្រឡប់ទៅអាតែនវិញក្នុងឆ្នាំ៣៥៦មុនគ.ស ហើយបានបន្តជីវិតចុងក្រោយរបស់លោក ក្នុងការបង្ហាត់បង្រៀន និង តែងនិពន្ធក្នុងសាលា អាកាដេមី របស់លោក ។ ចំពោះអំពើ របស់ដេនីស II បានជំរុញឱ្យ ឌីយ៉ុង សងសឹកត្រឡប់មកវិញ ។ ៤ឆ្នាំក្រោយមក គឺក្នុងឆ្នាំ៣៥៧ ឌីយ៉ុងបានដឹកនាំទាហានចំនួន៨០០នាក់ទៅកំចាត់ដេនីស II ចោលហើយកសាងរបបគ្រប់គ្រងមួយ ស្របតាមគំនិតរបស់ លោកប្លាតុង ពោលគឺ រៀបចំសុទ្ធតែ អ្នកប្រាជ្ញកំពូលៗ ឱ្យនៅជុំវិញខ្លួន ។ ប៉ុន្តែ២ឆ្នាំក្រោយមក ឌីយ៉ុង ត្រូវបានមនុស្សម្នាក់ ឈ្មោះ Callipe ដែលស្ថិតក្នុង បក្សពួកជាមួយគ្នា


www.elibraryofcambodia.org

លបធ្វើឃាត ដែលជាមូលហេតុធ្វើឱ្យសភាពការណ៍ ត្រូវធ្លាក់ទៅក្នុងសភាពអាប់អួរជាទីបំផុត ។

## II.គំនិតនយោបាយសំខាន់ៗ របស់លោកប្លាតុង

គំនិតនយោបាយរបស់លោក ត្រូវបានគេមើលឃើញច្បាស់ក្នុង ស្នាដៃសំខាន់ពីរគឺ La République និង Les Lois ។

- La République និយាយអំពីការរៀបចំបូរី ទៅតាមបែបមនោគតិ (Cité Idéale) ។ ចំណែកឯ Les Lois វិញលោករៀបចំបូរី ស្របទៅតាមការពិតជាក់ស្តែង (Réalité) ។ លោកបានទទួលស្គាល់ថា នយោបាយជើរតួសំខាន់បំផុត នយោបាយគឺជាវិទ្យាសាស្ត្រ ដ៏ខ្ពស់បំផុត (Science Royale) ដែលក្នុងនោះស្នាដៃដទៃទៀត ត្រូវស្ថិតនៅក្រោមនយោបាយទាំងអស់ ។

### ១-គំនិតនយោបាយស្តីពីយុត្តិធម៌

យុត្តិធម៌ គ្របដណ្តប់ទៅលើអ្វីដែលធំបំផុតនោះគឺ រដ្ឋ (Macrocosme) ដែលជានិច្ចកាលធំជាងបុគ្គល ហើយគឺជាគុណធម៌ទី៤ សំរាប់សង្គមទាំងមូល ។ លោកប្លាតុងស្លាប់មុនពេលបានឃើញអ្វី ដែលហៅថាបូរីក្នុងពិភពគំនិត ដែលជានិច្ចកាលលោកតែងតែនឹកស្រមៃ និងប្រាថ្នាចង់បាន ។ យុត្តិធម៌ គឺជាតម្លៃ



www.elibraryofcambodia.org

ខ្ពស់បំផុតនៃការរៀបចំបូរីឱ្យស្ថិតក្នុងលំនឹង និងសណ្តាប់ធ្នាប់ ។ ដូច្នេះត្រូវរៀបចំ មនុស្សម្នាក់ៗ ឱ្យស្ថិតនៅតាមកន្លែង និងរៀបចំឱ្យទៅតាមអ្វី ដែលមនុស្សទាំងនោះត្រូវធ្វើ ទើបធានាបាននូវយុត្តិធម៌ ។

## *២-គំនិតនយោបាយស្តីពីវណ្ណៈ

តាមគំនិតរបស់លោក បូរីដែលត្រឹមត្រូវបំផុតគប្បីមានមុខងារដែលផ្សារភ្ជាប់ទៅនឹង មុខងាររបស់វណ្ណៈទាំងបី ដូចខាងក្រោមនេះ :

- **វណ្ណៈពលករ :** បានដល់ពួកសិប្បករ ពាណិជ្ជករ កសិករ កម្មករ និងឈ្មួញដែលជាវណ្ណៈមូលដ្ឋាន ។ វណ្ណៈនេះត្រូវមាន គុណធម៌មួយគឺ ការគោរពតាម និងការចេះប្រមាណ (Tempérance)
- **វណ្ណៈមធ្យម :** គឺពួកទាហាន(Les soldats) ដែលជា អ្នកការពារបូរីប្រឆាំងនឹង ការឈ្លានពានពីខាងក្រៅ ។ គុណធម៌របស់វណ្ណៈនេះ គឺ សេចក្តីក្លាហាន ។
- **ពួកទស្សនវិទូ :** ជាវណ្ណៈដែលខ្ពស់បំផុត ហើយក៏ជាវណ្ណៈសំរាប់ ដឹកនាំសង្គម និងដឹកនាំប្រជាពលរដ្ឋក្នុងបូរី ។ ពួកទស្សនវិទូអាចក្លាយទៅជា ស្តេចបានគេហៅម្យ៉ាងទៀតថាជា **ទស្សនវិទូ - ស្តេច** ។ គឺជា ផលិតផលនៃបញ្ញាញាណមិនចេះចប់ ដែលបាន


www.elibraryofcambodia.org

មកពី ការរៀនសូត្រ ។ នៅអាយុ៣០ឆ្នាំ ត្រូវរៀនសូត្រពីបដិច្ចសមុប្បាទ (ទ្រឹស្តីដែលភ្ជាប់ទៅ នឹងហេតុផល) ហើយត្រូវបញ្ចប់ក្នុងអាយុ៣៥ឆ្នាំ ។ ចាប់ពីអាយុ៣៥ ដល់ ៥០ឆ្នាំ គឺជាអាយុកាលដែលត្រូវដឹកនាំបូរី ។ ចាប់ពីអាយុ៥០ឆ្នាំ ឡើងទៅអាចបំរើការងារក្នុង អំណាចរដ្ឋបាល ឬ អំណាចតុលាការ ហើយអាចត្រឡប់ទៅសិក្សាម្តងទៀត ។

គតិបណ្ឌិត គឺ ជាគុណធម៌របស់អ្នកគ្រប់គ្រង ។ លោកបានបញ្ចូល គុណធម៌គ្រិកបូរាណ (ការចេះប្រមាណ សេចក្តីក្លាហាន គតិបណ្ឌិត និងយុត្តិធម៌ ) ទៅក្នុងរចនាសម្ព័ន្ធរបស់វណ្ណៈ ក្នុងបូរីរបស់លោក ។ លោកបានគូសបញ្ជាក់ជាចុងក្រោយថា បូរីដែលត្រឹមត្រូវគឺជាបូរី ដែលវណ្ណៈនីមួយៗ ក្នុងបូរីនោះអនុវត្តមុខងាររបស់ខ្លួនបានល្អ មិនមានការរំលោភទៅលើសកម្មភាព របស់វណ្ណៈដទៃ ។ បើធ្វើបានយ៉ាងនេះ គឺមានយុត្តិធម៌ ។ ចំណុចសំខាន់នៃគំនិតនយោបាយនេះគឺ ទស្សនវិទូជា អ្នកបញ្ជាតែមួយគត់ ដែលប្រកបដោយសមត្ថភាពគ្រប់គ្រង យល់ដឹងបានពីសច្ចភាព និងប្រព្រឹត្តអំពើប្រកបដោយគុណធម៌ ។ លោកបានគិតផងដែរ ទៅលើអំណាចដែលចេញមកអំពីចំណេះដឹង។ អំណាច និងចំណេះដឹងត្រូវតែផ្សារភ្ជាប់គ្នា ។


www.elibraryofcambodia.org

ក្នុងប៉ូវីលោកចង់បង្កើតឱ្យមានសហគមន៍ស្ត្រី និង កុមារដែលទទួលការហ្វឹកហាត់ដូចគ្នា ខាងកាយសម្បទា និងបញ្ញា ។ លោកចង់ ឱ្យស្ត្រីមានសិទ្ធិស្មើគ្នាដូចបុរស ក្នុងការបំរើប៉ូវី ក៏ដូចជាវិស័យអប់រំ។

## ៣-គំនិតនយោបាយស្តីពីរបបគ្រប់គ្រង

តាមគំនិតរបស់លោក របបគ្រប់គ្រងអាចមានរូបភាព៣យ៉ាង :

- រាជាធិបតេយ្យ (Monarchie) ដែលលោកចាត់ទុកថា ជារដ្ឋាភិបាលមួយ ស្ថិតក្រោមអំណាចរបស់មនុស្សម្នាក់ ។ ជននោះមិនអាច កាត់ផ្តាច់ចេញពីរបបអភិជនាធិបតេយ្យ ដែលជារបបដឹកនាំដោយ រដ្ឋាភិបាលរបស់អ្នកខ្ពង់ខ្ពស់ (អភិជន) ដែលគិតគូរពីផលប្រយោជន៍រួម ។

- រដ្ឋាភិបាលយោធា ដឹកនាំដោយពួកទាហាន ។ របបនេះអាចក្លាយបន្តិចម្តងៗ ទៅជារបបអប្បជនាធិបតេយ្យ ដែលដឹកនាំដោយមនុស្សមួយក្រុមដំណាងឱ្យមហិច្ឆិតា និងការលោភលន់ ។

- រដ្ឋាភិបាលប្រជាធិបតេយ្យ ឬ រដ្ឋាភិបាលដឹកនាំដោយមនុស្សភាគច្រើនដែលជាជនក្រីក្រ គឺជារបបប្រកបដោយតណ្ហា ។ របបនេះ អាចកើតមានឡើងជាការប្រព្រឹត្តិខុសសីលធម៌ ការខ្ជះខ្ជាយការប្រកួតប្រជែងនៃបក្សពួកនីមួយៗ ។


www.elibraryofcambodia.org

ដូច្នេះហើយ អាចក្លាយទៅជា របបផ្តាច់ការនៅថ្ងៃណាមួយ ហើយជាចុងក្រោយទៅជា របបរាជាធិបតេយ្យ ។ ការបន្តជាប់មិនដាច់នៃរបបនីមួយៗ ក្នុងលក្ខណៈរលំរលាយ នឹងកើតឡើងសាជាថ្មីនោះ បានឆ្លុះបញ្ចាំងនូវគំនិតសាចុះសាឡើងរបស់ពិភពលោក (Conception cyclique du monde) ដែលជាចរិតលក្ខណៈនៃការគិតគូររបស់ពួកក្រិក ។

## ៤-គំនិតនយោបាយស្តីពីច្បាប់

ច្បាប់ ជាពិសេសគឺច្បាប់ព្រហ្មទណ្ឌ មានតួនាទីពយ៉ាងគឺ អប់រំ បង្ការ និង ព្យាបាល ។ ចៅក្រមគឺជាគ្រូពេទ្យនៃព្រលឹង ។ លោកបាន ប្រៀបធៀបយ៉ាងដូច្នេះថា "អ្នកប្រព្រឹត្តខុស តែងតែប្រកែកប្រណាំង ជាមួយចៅក្រមជានិច្ច វិស័យដូចជាអ្នកជម្ងឺតែងតែប្រកែកប្រណាំងជាមួយគ្រូពេទ្យយ៉ាងដូច្នោះដែរ " ។

ច្បាប់ មិនអាចចាត់ទុកថាត្រឹមត្រូវឥតខ្ចោះនោះទេ ពីព្រោះច្បាប់ជាស្នាដៃរបស់មនុស្ស ដូច្នេះដើម្បីឱ្យមានភាពល្អឥតខ្ចោះ ច្បាប់ ត្រូវខិតចូលជិតច្បាប់របស់អាទិទេព ។

ច្បាប់ ជាឧបករណ៍ដែលស្ថិតក្នុងកណ្តាប់ដៃនៃអ្នកដឹកនាំ ដែលរៀបចំឡើងអាស្រ័យដោយតម្រូវការនៃបេសកកម្ម របស់ខ្លួន ។



www.elibraryofcambodia.org

## ៥-គំនិតនយោបាយស្តីពីសាសនា

សាសនា មានភាពចាំបាច់បំផុត ។ សាសនាអាចពង្រឹងនូវការរួបរួមគ្នា រវាងសមាជិកក្នុងបូរី ។ សាសនាអាចញ៉ាំងឱ្យមានការស្តាប់បង្គាប់ និងការគោរពចំពោះអាជ្ញាធរ ។

## ៦-គំនិតនយោបាយស្តីពីនយោបាយ និងការអប់រំ

លោកបានអះអាងថា នយោបាយមិនអាចកាត់ផ្តាច់ចេញពីការអប់រំឡើយ ។ ការអប់រំ គឺជាមធ្យោបាយដើម្បីញ៉ាំងឱ្យបូរីមានភាពល្អប្រសើរ ធានាបាននូវលំនឹងសណ្តាប់ធ្នាប់ និងការស្រុះស្រួលគ្នា។ គេអាចអប់រំពលរដ្ឋ ឱ្យយល់ដឹង និង ទទួលយកនូវគោលដៅរបស់បូរី ហេតុដូច្នេះហើយ ការអប់រំក៏មានលក្ខណៈនយោបាយហើយ នយោបាយក៏ជាសិល្បៈ ដើម្បីដឹកនាំ និងគ្រប់គ្រងមនុស្សជាមួយនឹងការស្រុះស្រួលគ្នារបស់ពួកគេ ។ ការអប់រំត្រូវធ្វើតាមរយៈកំណាព្យរបស់កវីល្បីៗដែលមានចរិតនយោបាយ និងចរិតអប់រំយ៉ាងជ្រាលជ្រៅ ហើយរៀប ចំជាបាវចនាសំខាន់ៗ ទៅដាក់នៅតាមក្លោងទ្វាររបស់បូរី ។

ឧៈ បាវចនារបស់អាតែន ដ៏ល្បីល្បាញ ក្នុងសម័យបុរាណ គឺ **សេរីភាព សមភាព** និង **ភាតរភាព** ( Liberté Egalité et Fraternité) ។



www.elibraryofcambodia.org

បាវចនារបស់ធ្លាតុង ដាក់នៅលើស៊ុមទ្វារចូលរបស់ អាកាដេមី គឺ "**គ្មានអ្នកណាចូលមកកាន់ទីនេះ ដោយមិនមែនជាអ្នក ធរណីមាត្រ ឡើយ**"(Que nul n'entre ici qui ne soit géomètre) ។ ក្រៅពីនោះ ក៏មានបាវចនាសំខាន់ៗ ខ្លះទៀតដូចជា "**អ្នកចង់បាន អំណាច មិនសក្តិសមនឹង ទទួលឡើយ**" "**អ្នកដែលសក្តិសមនឹង ទទួល អំណាច មិនចង់បានអំណាចឡើយ**" " Celui qui veut le pouvoir ne le mérite pas , celui qui le mérite ne le veut pas "។

## ៧-គំនិតនយោបាយស្តីពីកម្មសិទ្ធិ និងគ្រួសារ

តាមគំនិតរបស់លោក កម្មសិទ្ធិ និង គ្រួសារគឺជាធាតុ ដែលនាំទៅដល់ចំណង់អត្តទត្ថ ។ គឺជាមេនាំអាទិ៍ឱ្យមានការបែកបាក់ និង អំពើពុករលួយដែលចាំបាច់ត្រូវតែលុបបំបាត់។ គ្រួសារធ្វើឱ្យមនុស្ស មានចិត្តទន់ជ្រាយ ។ កម្មសិទ្ធិបំបែកមនុស្សធ្វើឱ្យមនុស្សបែកខ្ញែក គ្នា។ កុមារត្រូវបំបែកចេញពីឪពុកម្តាយ តាំងពីកើតមកដើម្បីទទួល យកការអប់រំជាសមូហភាពតាមបែបយោធា ។ ចំពោះវណ្ណៈអ្នក ចំបាំងត្រូវឱ្យ រស់នៅដោយលះបង់ឱ្យដាច់ស្រឡះពីធាតុទាំងពីរ ។ ទីមួយ ហាមមិនឱ្យពាក់គ្រឿងអលង្ការនៅនឹងខ្លួន ក៏ដូចជា : ប្រើប្រាស់ គ្រឿងប្រាក់នៅលើតុ ។ បើមានយ៉ាងនេះថ្ងៃណាមួយ



www.elibraryofcambodia.org

ដែលមានការយុទ្ធគ្នាកើតឡើង អ្នកទាំងនោះមិនអាចការពារអ្វី ក្រៅពីទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ។ អាពាហ៍ពិពាហ៍កងទ័ព គឺជាកិច្ចការរបស់រដ្ឋ មិនមែនជាកិច្ចការរបស់គ្រួសារឡើយ ។ តុលាការ ឬ ចៅហ្វាយក្រុងជាអ្នកសំរេច ដោយមានកំណត់ អាយុសំរាប់អាពាហ៍ពិពាហ៍ ។ បុរសអាចរៀបការបានក្នុងចន្លោះអាយុ ពី២០ ទៅ៤០ឆ្នាំ ។ ប៉ុន្តែអាចមានការលើកទឹកចិត្តចំពោះវណ្ណៈ ដោយអាចឱ្យគេមានសិទ្ធិជ្រើសរើស គូស្រករដោយខ្លួនឯង ប៉ុន្តែកូនកើតមក គឺ ស្ថិតនៅក្រៅច្បាប់ និង ក្រៅវណ្ណៈ ។ កូនដែលកើតមកមិនគ្រប់លក្ខណៈ ឬ ស្រឡាញ់មាសប្រាក់ក្រៅពីគ្រឿងសាស្ត្រាវុធ ត្រូវបានគេ យកទៅទុកចោលឱ្យស្លាប់ ដោយទំលាក់កំហុសទៅលើការថែទាំមិន ដិតដល់ ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកអារីស្តូត(Aristote)

## ៣៨៤-៣២២ មុនគ.ស

## I.ជីវិតនិងចរិតលក្ខណៈ



- លោកអារីស្តូតកើតនៅ ស្តាហ្សៀ (Stagire) ស្ថិតនៅភាគខាងជើង ខេត្តកាល់ស៊ីឌិច (Chalcidique) ជាប់សមុទ្រ អេហ្សេ (Egée) ជិតប្រទេសម៉ាសេដូន (Macédoine) ។

-ឪពុករបស់លោកឈ្មោះនីកូម៉ាក(Nicomaque) ជាគ្រូពេទ្យព្យាបាលជម្ងឺព្រះចៅអាមីនតាស II(Amintas II) នៅម៉ាសេដូន ។



www.elibraryofcambodia.org

-ឪពុករបស់លោកចង់ឱ្យរូបលោកក្លាយទៅជាវេជ្ជបណ្ឌិត ប៉ុន្តែខ្លួនលោកមានចំណង់ចំណូលចិត្តខាងផ្នែក វិទ្យាសាស្ត្រសង្គម ។ លោកបានទទួលមរតកពីឪពុករបស់លោក ដែលជាគ្រូពេទ្យធ្វើឱ្យលោកចេះវិជ្ជាពេទ្យដូចជាឪពុករបស់លោកដែរ ប៉ុន្តែដោយលោកមានចំណង់ចំណូលចិត្ត ខាងផ្នែកវិទ្យាសាស្ត្រសង្គម ធ្វើឱ្យលោកមាន ចរិតពូកែសង្កេតដោយធ្វើការពិចារណារកហេតុផល ។

- អាយុបាន១៧ឆ្នាំ លោកទៅនៅទីក្រុងអាតែន ហើយបានចូល រៀននៅសាលា អាកាដេមី(Académie) របស់លោកប្លាតុងអស់រយៈពេល២០ឆ្នាំ ។

- ឆ្នាំ៣៥៥ មុនគ.ស លោកបានបង្កើតសាលា របស់លោកមួយ ឈ្មោះ ឡី លីសេ (Le Lycée) ។

- លោកជាសាវ័ក (កូនសិស្ស របស់ប្លាតុង ប៉ុន្តែលោកមានគំនិត ខុសគ្នាជាមួយគ្រូរបស់លោក ។ លោកប្លាតុង មានគំនិតមនោនិយម (Idéalisme) ឯលោកអារីស្តូតមាន គំនិតប្រាកដនិយម(Réalisme) ។ លោកអារីស្តូត បានសិក្សាស្រាវជ្រាវអំពីពិភពបរានុម័ត (Monde objectif ) ដោយផ្អែកលើសារជាតិ (Essence) គុណភាព (Qualité) បរិមាណ (Quantité)


www.elibraryofcambodia.org

កាល (Temps) លំហ (Espace) ទីតាំង (Position) និង ស្ថានភាព (Situation) ។

- ដើម្បីពិចារណាទៅលើអង្គវត្ថុមួយ លោកតែងចោទសំណួរបីគឺ : ជាអ្វី ? នៅទីណា ? នៅពេលណា ?

- លោកអារីស្តូត ទិទៀនគំនិត កុម្មុយនិស្តនិយមស្តីពី ទ្រព្យសម្បត្តិ របស់ប្លាតុង ( Communisme des biens ) និង កុម្មុយនិស្តនិយមទៅលើស្ត្រី(Communisme des femmes)។ លោកអនុញ្ញាតឱ្យប្រើប្រាស់ កម្មសិទ្ធិឯកជន ដោយឈរលើច្បាប់ធ្វើជាគោលការណ៍រួម ។ លោកបានបញ្ជាក់ថា ពលរដ្ឋទាំងអស់អាចមានរបបកម្មសិទ្ធិឯកជន ពីព្រោះវាស្របនឹង ធម្មជាតិរបស់មនុស្សម្នាក់ៗ ។ មនុស្សម្នាក់ ៗ សុទ្ធតែស្រឡាញ់ខ្លួនទាំងអស់ ដូច្នេះកម្មសិទ្ធិឯកជនគឺជាប្រភព នៃការស្រឡាញ់ខ្លួននោះឯង ។

- លោកបានគិតថា អ្នកមានទ្រព្យត្រូវតែប្រកបដោយគុណធម៌ និង មានចិត្តសប្បុរស (សទ្ធាទាន) ។

- លោកមានការព្រួយបារម្ភ ចំពោះវិសមភាព ដ៏សែនជ្រៅមួយ ក្នុងសង្គម ពីព្រោះថា វិសមភាពអាចបង្កឱ្យមានការតូចចិត្តទំនាស់សង្គម ហើយធ្ងន់ធ្ងរទៅទៀតនោះគឺ ការធ្វើរដ្ឋប្រហារគ្រប់រូបភាព ដើម្បីផ្តួលរំលំរដ្ឋ ។



www.elibraryofcambodia.org

## II. ស្នាដៃ

លោកបានសរសេរស្នាដៃសំខាន់ពីរ :

**១.រដ្ឋធម្មនុញ្ញ (Constitution)**

- ក្នុងឆ្នាំ៣២៥ មុនគ.ស លោកបានចាប់ផ្តើម ប្រមូលផ្តុំចងក្រង រដ្ឋធម្មនុញ្ញរបស់ប្រទេស ឬ រដ្ឋសហព័ន្ធចំនួន១៥៨ តាមលក្ខណៈ អក្ខរក្រមព្រមទាំងធ្វើការវិភាគទៅលើរដ្ឋធម្មនុញ្ញ ទាំងនោះ ។ ប៉ុន្តែ រដ្ឋធម្មនុញ្ញទាំងនោះ មិនមាននៅសល់រហូតដល់សព្វថ្ងៃ ក្រៅពីរដ្ឋធម្មនុញ្ញរបស់បូរីអាតែន នោះឡើយ ។

**២.នយោបាយ(La Politique)**

- នេះគឺជាស្នាដៃទីពីររបស់លោក ។ ក្នុងស្នាដៃនេះលោកនិយាយជារួមអំពីការគ្រប់គ្រងប្រទេស និង ការពិនិត្យពិចារណាទៅលើ សមាសធាតុ(Composants) របស់បូរី ដូចជាការសិក្សាទៅលើ គ្រួសាររបស់ពលរដ្ឋក្នុងបូរី សិក្សាអំពីខណ្ឌសីមា សិក្សាអំពីប្រជាពលរដ្ឋ ឬក៏ពិនិត្យទៅលើ រដ្ឋាភិបាលរបស់បូរី ។

- ស្នាដៃស្តីពី "នយោបាយ" នេះគឺជា ក្បួនច្បាប់សំរាប់រដ្ឋពីព្រោះ លោកបានបង្ហាញអំពីអ្វី ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ


www.elibraryofcambodia.org

បុរាណផង និង លើកជាក្បួនច្បាប់ថ្មីផង តាមរយៈទស្សនវិជ្ជារបស់លោក ។ លោកក៏បានធ្វើការរិះគន់ផងដែរ អំពីអ្វីដែលមិនត្រឹមត្រូវ ក្នុងរដ្ឋធម្មនុញ្ញអស់ទាំងនោះ ហើយជំនួសនូវអ្វីដែលលោកយល់ឃើញថា ល្អប្រសើរ ។

## III. គំនិតនយោបាយរបស់លោកអារីស្តូត

លោកបានលើកឡើងនូវគំនិតនយោបាយសំខាន់ៗ ៦ គឺ :

### ១-សីលវិជ្ជា និង នយោបាយ

- ក្នុងស្នាដៃរបស់លោកអារីស្តូត នយោបាយឋិតនៅបន្ទាប់ពីសីលវិជ្ជា និង សេដ្ឋសាស្ត្រ ។

- លោកយល់ថា គោលដៅរបស់រដ្ឋាភិបាលគឺធ្វើឱ្យមនុស្សមានសីលធម៌ ។ នយោបាយចំណុះសីលធម៌ ។ ផ្ទុយមកវិញ នយោបាយគឺជាសិល្បៈ ឬ ជាវិទ្យាសាស្ត្រនៃការដឹកនាំបុគ្គល ។

- លោកចាត់ទុកថា មនុស្សធ្វើអ្វីៗដើម្បីសុភមង្គល ។ នេះគឺជាគោលការណ៍សីលធម៌សំរាប់មនុស្សម្នាក់ៗ ។ ប៉ុន្តែក្នុងលទ្ធភាពមួយចំនួន សុភមង្គលអាចកើតមានឡើងបាន បើសិនជាមនុស្សរស់នៅជា លក្ខណៈបុរី ។



www.elibraryofcambodia.org

- លោកបានលើកឡើងថា ស្ត្រីនិងបុរស បានរួមផ្គុំគ្នាបង្កើតបានជាគ្រួសារ ឬ ភូមិស្រុកដែលស្ថិតក្រោមអំណាចរបស់ឪពុក ។ នេះគឺជា គំរូទីមួយនៃអំណាចចំបងក្នុងគ្រួសារ ហើយជាចុងក្រោយគឺបូរីដែល ជាអ្នកបំពេញនូវអំណាចទាំងនោះ ។ ដូច្នេះមនុស្សគឺសត្វដែលមាន លក្ខណៈជាពលរដ្ឋ ។

- តាមគំនិតរបស់លោក បូរីនីមួយៗ មិនមែនសុទ្ធតែជា រដ្ឋយោធា ឬ ជារដ្ឋធ្វើជំនួញនោះទេ ។ សង្គ្រាមគឺជា មធ្យោបាយប៉ុណ្ណោះ ។ ការប្រើប្រាស់សង្គ្រាមត្រូវតែបន្ថយឱ្យនៅតិចបំផុត ។

-គោលដៅរបស់បូរីគឺមិនគ្រាន់តែធានារ៉ាប់រងឱ្យពលរដ្ឋម្នាក់ៗនូវស្បៀងអាហារប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានារ៉ាប់រង សុខុមាលភាព (Le bien-être) របស់ប្រជាពលរដ្ឋ ។ នយោបាយត្រូវបានរៀបចំឡើង ដើម្បីបង្កលក្ខណៈសម្បត្តិ និងការធ្វើឱ្យល្អប្រសើរឡើងនូវការរស់ នៅរបស់ប្រជាពលរដ្ឋ ។

- ភាពសំបូរទៅដោយធនធាន និងប្រាក់ចំណេញមិនធ្វើឱ្យ បូរីមានអានុភាពនោះទេ ។

- ជំនួញមិនទទួលស្គាល់ពិតប្រាកដថា ជាសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ ។



www.elibraryofcambodia.org

- គោលដៅរបស់នយោបាយ មិនមែនជាការធ្វើចំបាំង ឬជាការ មានបានជាទូទៅនោះទេ ប៉ុន្តែជាគុណធម៌រួម ។

- អ្នកដែលមិនធ្វើនយោបាយ មិនមែនជាមនុស្សទេ ។ អ្នកណាដែលមិនត្រូវការមនុស្សដូចគ្នា គឺជាអាទិទេព ឬ ពាក់កណ្ដាលអាទិទេព ឬក៏ជាសត្វទៀតផង ។

## ២-សេដ្ឋសាស្ត្រ (Economique)

- តាមន័យដើម របស់សេដ្ឋសាស្ត្រ គឺជា វិទ្យាសាស្ត្រនៃផ្ទះសំបែង (L'économique est une science de la maison) ចេញពី ពាក្យ Economique គឺពាក្យ Economie ដែលមានន័យថា សេដ្ឋកិច្ច ។

- វិទ្យាសាស្ត្រនៃផ្ទះសំបែង គ្របដណ្ដប់ទៅលើទំនាក់ទំនងសំខាន់ៗ បួនយ៉ាងគឺ :

- ទំនាក់ទំនងរវាងប្ដី និង ប្រពន្ធ ។
- ទំនាក់ទំនងរវាងឪពុក និង កូន ។
- ទំនាក់ទំនងរវាងម្ចាស់ទាសករ និង ទាសករ ។
- ទំនាក់ទំនងរវាងម្ចាស់ផ្ទះ និង អ្នកដទៃសំដៅដោះស្រាយ សំភារៈចាំបាច់ចំពោះការរស់នៅ ។



www.elibraryofcambodia.org

## ៣-រដ្ឋ

រដ្ឋជាសមិទ្ធិផលធម្មជាតិ។ រដ្ឋជាផលិតផលនៃដំណើររីកចំរើនរបស់ធម្មជាតិ ។

រដ្ឋជាសមាគម ឬ សហគមន៍ ដ៏ខ្ពស់បំផុតបើប្រៀបធៀបជាមួយគ្រួសារ ឬ ភូមិស្រុក ។ មនុស្សគឺជា សត្វចេះធ្វើនយោបាយទៅតាម ធម្មជាតិរបស់ខ្លួន ។ ផ្តើមចេញពីលក្ខណៈធម្មជាតិ មនុស្សបាននាំមកនូវសេចក្តី ប្រាថ្នាបែបសភាវគតិ ដើម្បីឈានទៅរកការរួមរស់ជាមួយគ្នា ។ មុនស្សមិនអាចរស់នៅតែម្នាក់ឯងបានឡើយ ។ មនុស្សត្រូវការ នូវទំនាក់ទំនង រវាងគ្នា និងគ្នា ដើម្បីបង្កើតជារដ្ឋរបស់ខ្លួនក្នុងគោលបំណងការពារ សុវត្ថិភាព និង ជំរុញឱ្យសង្គមរីកចំរើន ។

រដ្ឋជាផ្លែផ្កានៃយុត្តិធម៌ ជាអង្គការដែលគិតគូរពីផលប្រយោជន៍រួមសំរាប់ពលរដ្ឋ និង ការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។

រដ្ឋអាចធ្វើដំណើរទៅរកទីបញ្ចប់បាន ។ ភាពក្រីក្រគឺជា ដើមហេតុនៃការបដិវត្តន៍ និង ទោសឧក្រិដ្ឋគ្រប់បែបយ៉ាង ។ នៅពេលណាដែលគ្មានវណ្ណៈកណ្តាលទេនោះ ហើយអ្នកក្រីក្រកាន់តែច្រើនឡើង ភាពរីករវនឹងកើតមានឡើង ហើយរដ្ឋអាចឈានទៅរកទីបញ្ចប់ បាន **( Poverty is the parent of revolution and**



www.elibraryofcambodia.org

crimes, that when there is no middle class, and the poor greatly exceed in number, troubles arise and the state soon comes to an end ).

## ៤-អំណាច

តាមគំនិតរបស់លោក អំណាចទាក់ទងទៅនឹងការរៀបចំ និង ដឹកនាំ បុរី ។

ការរៀបចំត្រូវឋិតនៅលើគ្រួសារ និង ការងារ ។ គ្រួសារគឺជាផែនគ្រឹះនៃបុរី ។ គ្រួសារត្រូវឋិតនៅក្រោមអំណាចរបស់ឪពុក ។ ទាក់ទងទៅនឹងគ្រួសារ លោកមិនអនុញ្ញាតឱ្យរៀបការ ប្តីប្រពន្ធដោយចាប់ឆ្នោតនោះឡើយ។ លោកបានកំណត់ឱ្យស្ត្រីរៀបការនៅអាយុ ១៨ឆ្នាំ ឯបុរសគឺ៣៧ឆ្នាំ ហើយអាចបន្តដល់ អាយុ៥០ឆ្នាំចំពោះស្ត្រី និង ៥៥ឆ្នាំចំពោះបុរស ។ ស្ត្រីត្រូវមានគភ៌នៅរដូវរងារហើយត្រូវ ឆ្លងទន្លេនៅរដូវស្លឹកឈើជ្រុះដើម្បីជៀសវាងកុំឱ្យជួបនូវអាកាសធាតុ ក្តៅខ្លាំង ឬ រងារខ្លាំងពេក ។

លោកបានកំណត់ នូវកាតព្វកិច្ច តាំងពីកើតមក រហូតដល់អាយុ៧ឆ្នាំ បន្ទាប់មក ក្នុងវ័យចេះគិតគូរ និង ក្រោយមកទៀត ។ លោកបានផ្តោត ការគិតគូរជាសំខាន់ទៅលើការបណ្តុះបញ្ញា និង រៀនខាងសិល្បៈ ជាពិសេសខាងដូរ្យតន្ត្រី ។

លោកបានដកអំណាចពីបុគ្គលម្នាក់ៗ ហើយប្រគល់អំណាច


www.elibraryofcambodia.org

នោះឱ្យទៅច្បាប់វិញ ពីព្រោះបើធ្វើបានដូច្នេះអំណាចមានលក្ខណៈទូទៅ ល្អប្រសើរ និងមានកំរិតខ្ពស់ជាងអំណាចនៅលើបុគ្គល ។ ការដឹកនាំបូរី ត្រូវឋិតនៅលើរដ្ឋាភិបាល ដែលមានរូបភាពបីជាសំខាន់គឺ : រាជាធិបតេយ្យ (Monarchie) អភិជនាធិបតេយ្យ (Aristocratie) និង សាធារណរដ្ឋ(République)។ លោកមិនបានផ្តោតការនិយមចូលចិត្តទៅលើរូបភាពរដ្ឋាភិបាលណាមួយទេ។ ប៉ុន្តែ ក្នុងមនោគតិរបស់លោក (L'Ideal) គឺរបបចំរុះ (Régime mixte) ដែលជាការលាយបញ្ចូលគ្នារវាងអភិជនាធិបតេយ្យ និង សាធារណរដ្ឋ ដែលក្នុងនោះអំណាចនីតិបញ្ញត្តិ ត្រូវទុកឱ្យប្រជាពលរដ្ឋ (បរិមាណច្រើន) ហើយអំណាចនីតិប្រតិបត្តិទុកឱ្យអ្នកដែលមាន បរិមាណតិច ។ ដូច្នេះ លោកអារីស្តូតជាអ្នកផ្តើមគំនិតក្នុងការបែងចែកអំណាច ។

**៥-ការប្រែប្រួលនៃអំណាច(Transformation du pouvoir)**

អំណាចទាំងអស់មិនមានជីវិតអមតៈទេ តែអំណាចទាំងនោះអាចរលំរលាយទៅបានដោយសារមូលហេតុជាច្រើន :

• **មូលហេតុចំបង** : ខ្វះសមភាពក្នុងសង្គម ឬ ខ្វះយុត្តិធម៌ក្នុងសង្គម ។ សមភាព មិនអាចធ្វើបានមួយរយភាគរយទេ ប៉ុន្តែយើងក៏មិនត្រូវពង្រីកឱ្យមាន វិសមភាពមួយធំពេកដែរ ។



www.elibraryofcambodia.org

- អំពើផ្តាច់ការ ។

• **មូលហេតុបន្ទាប់បន្សំ :**

- ការបែងចែកវណ្ណៈក្នុងសង្គម : វណ្ណៈនីមួយៗ ឃ្លាតឆ្ងាយគ្នា ឬ ខុសគ្នាខ្លាំងពេក ធ្វើឱ្យមានទំនាស់ក្នុងសង្គម ហើយជាចុងក្រោយធ្វើ ឱ្យអំណាចនោះដួលរលំ ។ ត្រូវធ្វើឱ្យមានវណ្ណៈមធ្យមភាគច្រើនទើបអាចផ្សារភ្ជាប់គ្នាបានរវាងវណ្ណៈលើ និងវណ្ណៈក្រោម ទើបសង្គមនោះ អាចបន្តស្ថិតស្ថេរទៅបាន ។

- មូលហេតុផ្ទាល់ខ្លួននៃអ្នកកាន់អំណាច : ការបំពានទៅលើអំណាច របស់អ្នកដទៃ ឬ ជាន់ឈ្លីកិត្តិយសអ្នកដទៃ ។

- ការភ័យខ្លាចបាត់បង់អំណាច : ការដឹកនាំមិនល្អ នាំឱ្យមានអ្នកប្រឆាំងច្រើន អំណាចត្រូវដួលរលំ ។

## ៦-ចំណាត់ថ្នាក់រដ្ឋាភិបាល

លោកយល់ឃើញថា រដ្ឋាភិបាលដែលមិនល្អ មិនចាំបាច់តែរដ្ឋាភិបាលដែលដូចគ្នាគ្រប់ពេលវេលា ឬ ក៏គ្រប់ប្រទេសនោះទេ ។ លោកបានធ្វើការបែងចែករដ្ឋាភិបាលជាពីរក្រុម :

• **ក្រុមរដ្ឋាភិបាលល្អបរិសុទ្ធ**



www.elibraryofcambodia.org

- រដ្ឋាភិបាលដឹកនាំដោយមនុស្សម្នាក់ដើម្បីបំរើផលប្រយោជន៍មនុស្សទាំងអស់ក្នុងបុរី (រាជាធិបតេយ្យ Monarchie) ។

- រដ្ឋាភិបាលដឹកនាំដោយមនុស្សមួយចំនួនតូច ដើម្បីបំរើឱ្យផលប្រយោជន៍បុរី (អភិជនាធិបតេយ្យ Aristocratie)

ក្រុមទាំងពីរនេះជាក្រុមល្អឥតខ្ចោះ

- រដ្ឋាភិបាលដឹកនាំដោយមនុស្សភាគច្រើន ដើម្បីបំរើឱ្យផលប្រយោជន៍ បុរីជារួម (ក្រុមសាធារណរដ្ឋ République ou politie)

## • ក្រុមមិនបរិសុទ្ធ

- រដ្ឋាភិបាលដឹកនាំដោយមនុស្សតែម្នាក់ ដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន (រដ្ឋាភិបាលផ្តាច់ការ Tyrannie) ។

- រដ្ឋាភិបាលដឹកនាំដោយមនុស្សមួយក្រុម ដែលបំរើផលប្រយោជន៍របស់ក្រុមខ្លួន(អប្បជនាធិបតេយ្យ Oligarchie) ។

- រដ្ឋាភិបាលដឹកនាំដោយមនុស្សភាគច្រើនប្រឆាំងនឹងអ្នកមាន (ប្រជាធិបតេយ្យ Démocratie) ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកប៉ូលីប(Polybe)

## ២០៤-១២២ មុនគ.ស

## ឬ ២០០-១៨៨ មុនគ.ស

## I.ជីវិតនិងចុក្ខលិកលក្ខណៈ



- លោកត្រូវបានគេទទួលស្គាល់ថា ជា មហាប្រវត្តិវិទូក្រិក និង ជារដ្ឋបុរស ដ៏ក្មេងម្នាក់របស់ក្រិកបន្ទាប់ពីលោក ហេរ៉ូដូត និងទុយស៊ីឌីដ ។

- លោកកើតនៅ មេហ្គាលីស ។ ឪពុករបស់លោកឈ្មោះលីកំរតាស ជាអ្នកមានម្ចាស់ដី និងជាឥស្សរជនដ៏ ល្បីល្បាញរបស់ក្រិក ។

- លោកចូលចិត្តជិះសេះបរបាញ់សត្វ ។

- លោកចូលចិត្តសង្កេត និងធ្វើការប្រៀបធៀប ។

- លោកបានផ្តោតអារម្មណ៍ទៅលើកិច្ចការយោធា ហើយបានក្លាយជាមេបញ្ជាការទ័ពសេះក្នុងចន្លោះឆ្នាំ ១៧០-១៦៧មុនគ.ស ។


www.elibraryofcambodia.org

- បន្ទាប់ពីរ៉ូម ទទួលជ័យជំនះក្នុងសង្គ្រាមជាមួយម៉ាសេដនពួកឥស្សរជនក្រិក ពិសេសពួកអាកេអៀងចំនួន១០០០នាក់ រួមទាំងលោកប៉ូលីប ត្រូវបានគេបញ្ជូនទៅកាន់ទីក្រុងរ៉ូម ក្នុងឋានៈជាអ្នកទោសនយោបាយ ប៉ុន្តែអ្នកទាំងនោះពុំត្រូវបានអាជ្ញាធរទីក្រុងរ៉ូម កាត់ទោសម្តងណាឡើយ ។

- នៅទីក្រុងរ៉ូម លោកមានភ័ព្វសំណាង បានរស់នៅក្នុងផ្ទះឧត្តមសេនីយ៍ម្នាក់ ឈ្មោះ ស៊ីព្យូរអាមីលីយ៉ានូស ហើយបានក្លាយទៅជា អ្នកបីបាច់រក្សា និង បង្ហាត់បង្រៀនកូនប្រុស របស់លោកឧត្តមសេនីយ៍ ។

- លោកត្រូវបាន លោកឧត្តមសេនីយ៍ពេញចិត្តយ៉ាងខ្លាំង ។ រាល់ដំណើរបេសកកម្មការទូត និងយោធាទៅបរទេស ដូចជាទៅប្រទេស អេស្ប៉ាញ អាស៊ី និង អាហ្វ្រិក លោកតែងតែនាំប៉ូលីបទៅជាមួយ ។ អាស្រ័យដោយហេតុផលបែបនេះហើយ ទើបប៉ូលីបអាចមាន សមត្ថភាពពិនិត្យទៅលើ កិច្ចការរបស់អ្នកនយោបាយរូបនេះ ហើយតែងតែចោទសួរខ្លួនឯងថា តើហេតុអ្វីបានជារ៉ូមអាចរីកលូតលាស់បាន តាំងពីបូរីដ៏តូចមួយ រហូតដល់ក្លាយទៅជាមហាអំណាចមួយនៅលើ ពិភពលោកនាសម័យនោះ ។

- លោកតែងតែកោតសរសើរទៅលើអរិយធម៌ ដ៏រុងរឿងរបស់


www.elibraryofcambodia.org

រ៉ូម និងរដ្ឋបុរសទាំងឡាយខាងផ្នែកយោធារបស់រ៉ូមថែមទៀតផង។

- ក្នុងឆ្នាំ១៥១មុនគ.ស បន្ទាប់ពីរស់នៅបាន១៦ឆ្នាំ ឥស្សរជនរបស់ក្រិក ដែលនៅរស់រានមានជីវិតចំនួន៣០០នាក់ ត្រូវបានគេដោះលែង ហើយបញ្ជូនត្រឡប់មកប្រទេសក្រិកវិញ ។ ទោះបីជាយ៉ាងនេះក្តី ក៏ប៉ូលីបមិនបានត្រឡប់មកវិញទេ ហើយបានរួមដំណើរជាមួយស៊ីព្យូ ក្នុងយុទ្ធនាការសង្គ្រាមមួយនៅកាកតាស្ស (អាហ្វ្រិកខាងជើង) ក្នុងឆ្នាំ១៤៦មុនគ.ស ។

## II.ស្នាដៃ

- ស្នាដៃដ៏ធំធេងរបស់លោក ឋិតនៅក្នុងដំណាក់កាល ចុងក្រោយនៃជីវិតរបស់លោក ។ ស្នាដៃនោះមានឈ្មោះថា "ប្រវត្តិសាស្ត្រសកលលោក" ដែលមានចំនួន៤៩ក្បាល ។ ក្នុងស្នាដៃដ៏ធំនេះ លោកចង់បង្ហាញឱ្យឃើញនូវហេតុផល ដែលធ្វើឱ្យប្រទេសប្រកបដោយ អរិយធម៌នៅលើសកលលោក បែរជារលំរលាយហើយត្រឡប់ មកនៅក្រោមអំណាចគ្រប់គ្រងរបស់រ៉ូម ។ ស្នាដៃរបស់លោកបាន គ្របដណ្តប់ទៅលើសម័យមួយ ដែលឋិតនៅក្នុងរយៈពេល៥៣ឆ្នាំ ប៉ុណ្ណោះពោល គឺនៅចន្លោះឆ្នាំ ២១៩-១៦៧ មុនគ.ស ។


www.elibraryofcambodia.org

- ក្រៅពីនេះលោកបានផ្តល់គំនិតមួយដ៏សំខាន់ទាក់ទងដល់ការសិក្សារៀនសូត្រប្រវត្តិវិទ្យា ។ លោកបានលើកឡើងថា គ្រប់ប្រវត្តិវិទូទាំងអស់ ត្រូវសង្កត់ធ្ងន់ទៅលើការអប់រំនិងការបង្ហាត់បង្រៀន។ ការបង្ហាត់បង្រៀន ត្រូវផ្តោតទៅលើសកម្មភាពនយោបាយមិនមែនគ្រាន់តែធ្វើឱ្យអ្នកស្តាប់រំជួលចិត្ត ដោយក្តីរំភើបដូចជាការតែងនិពន្ធរឿងធម្មតានោះទេ ។

- ប្រវត្តិវិទ្យា ត្រូវមានគោលការណ៍ច្បាស់លាស់ ពោលគឺបង្ហាញ ការពិតរបស់ព្រឹត្តិការណ៍ ឬនិយាយពីការពិតណាមួយដើម្បីបង្ហាត់ បង្រៀនដល់សិស្សរបស់ខ្លួនគ្រប់ពេលវេលា ។

## III.គំនិតនយោបាយសំខាន់ៗ

### ១-នយោបាយ

នយោបាយមិនមែនមានគោលដៅ ដើម្បីធានានូវការមានបានប៉ុណ្ណោះទេ ប៉ុន្តែនយោបាយត្រូវធានាឱ្យពលរដ្ឋម្នាក់ៗ អាចឈានទៅដល់គុណធម៌ និងគតិបណ្ឌិត ។ ជីវភាពសាធារណៈមាន គោលដៅដើម្បីបង្កើតនូវការស្រុះស្រួលគ្នា និងភាពយុត្តិធម៌ ។

លោកបានធ្វើការសិក្សាពីនយោបាយដោយផ្សារភ្ជាប់នយោបាយការបរទេសនយោបាយក្នុងប្រទេសទៅនឹងការអនុវត្តន៍ជាក់ស្តែង។


www.elibraryofcambodia.org

លោកបានសិក្សាពីការវិវត្តន៍នៃស្ថាប័ននយោបាយរបស់ចក្រភព រ៉ូម ហើយបានសន្និដ្ឋានថា ការលេចឡើងរបស់រ៉ូមដោយធ្វើដំណើរ ទៅកាន់ភាពឧត្តុងឧត្តមបំផុតក្នុងពិភពលោកគឺអាស្រ័យលើ**ការងារ** ដែលមានកិរិតស្តង់ដារនយោបាយ និង ការអនុវត្តន៍ខ្ពស់ ពុំមែន អាស្រ័យដោយរ៉ូមមានវរជនជាបុគ្គលខ្លាំងក្លាពីរ បីរូប ឬ មានមេ ដឹកនាំយោធាធំៗ ទាំងឡាយនោះទេ ។ លោកបានពិនិត្យឃើញថា ការកសាងឡើងនូវ ស្ថាប័នរបស់រដ្ឋ គឺជាកត្តាកំណត់មួយដើម្បី បង្កើត ឡើងនូវកំលាំងរបស់ជាតិ ។

ចំពោះលោកប្លាតុង និង លោកអារីស្តូត លោកទាំងពីរបាន សិក្សា អំពីស្ថាប័ននយោបាយ ដែលទាក់ទងដល់ការរស់នៅដ៏ល្អ របស់ សហគមន៍ក៏ដូចជាបុគ្គលម្នាក់ៗ ដែលទទួលខុសត្រូវលើ ចក្រភពក្រិច ដែលអនុវត្តរបបផ្តត់ផ្តង់ដោយខ្លួនឯង តាមរយៈរដ្ឋ បូរីហើយដែលវណ្ណៈនីមួយៗ ឋិតនៅដាច់ដោយឡែកពីគ្នា តាមមុខ នាទីរបស់ខ្លួន ។

## ២-ទំរង់រដ្ឋាភិបាល

លោកបានយល់ស្រប់ជាមួយលោកអារីស្តូត ដែលថាទំរង់រដ្ឋា ភិបាលមានបីគឺ : រាជាធិបតេយ្យ អភិជនាធិបតេយ្យ និង ប្រជា ធិបតេយ្យ ប៉ុន្តែលោកសង្កត់ធ្ងន់ថា ទំរង់នីមួយៗ អាចចុះអន់ថយ



www.elibraryofcambodia.org

ទៅ ដោយខ្លួនឯង បើសិនជាគ្មានគោលណ៍ត្រួតពិនិត្យ និងការថ្លឹងឱ្យមាន លំនឹងទេនោះ ហើយរបបប្រជាធិបតេយ្យ នឹងក្លាយទៅជារបបផ្ដាច់ការ របបអភិជនាធិបតេយ្យនឹងក្លាយទៅជា របបអប្បជនាធិបតេយ្យ ជាចុងក្រោយរបបប្រជាធិបតេយ្យ នឹងក្លាយទៅជាវិធានរបស់ ហ្វូងមនុស្ស ដែលដំណាងឱ្យកំលាំង និងហឹង្សា។ លោកអះអាងថា របបដែលល្អបំផុតនោះគឺ របបចំរុះ ដែលជារបបរួមបញ្ចូលគ្នានៃរបប ទាំងបីខាងលើ ពីព្រោះតាមរយៈរបបចំរុះនេះ គេអាចការពារបាននូវ អំណាចដ៏លើសលប់ របស់បុគ្គល ឬ របស់ផ្នែកណាមួយនៃរដ្ឋាភិបាល ។ ដូច្នេះហើយបានជាក្រោយពេលនោះជាច្រើនសតវត្សរ៍មកទៀត គេឃើញមានការ បែងចែកអំណាចដាច់ស្រឡះពីគ្នាក្នុងបណ្ដាប្រទេស ជាច្រើន រវាងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និង អំណាចតុលាការ ដូចជានៅសហរដ្ឋអាមេរិកជាដើម ។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកស៊ីសេរ៉ុង(Cicéron)

## ១០៦-៤៣ មុនគ.ស

### I .ជីវិតនិងបុគ្គលិកលក្ខណៈ



- លោកជាអ្នកនិពន្ធ អ្នកនយោបាយ ទស្សនវិទូ រដ្ឋបុរស និងជា វាគ្មិនប្រចាំទីក្រុង រ៉ូម ។

- លោកមានឈ្មោះមួយទៀតគឺ ម៉ាគូស ទុយលីយូស ។ គេហៅ លោកថា ទូលី ។



www.elibraryofcambodia.org

- លោកកើតនៅ អាកពីណូម ( សព្វថ្ងៃឈ្មោះ អាកពីណូ-អ៊ីតាលី ) ។

- តាំងពីវ័យកុមារ លោកមានចំណង់ចំណូលចិត្ត រៀនខាងច្បាប់ ខាងវាគ្មិន ទស្សនវិជ្ជា និង អក្សរសាស្ត្រ ។

- លោករៀនច្បាប់នៅទីក្រុងរ៉ូម រៀនទស្សនវិជ្ជានៅអាតែន ។

- លោកចូលបំរើកិច្ចការយោធា តែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។

- លោកបានបំរើកិច្ចការខាងច្បាប់ ក្នុងនាមជាឯកជន ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។

- លោកបានធ្វើដំណើរទៅបន្តការសិក្សា ក្នុងបណ្ដាប្រទេសនៅអាស៊ី ជាទីដែលលោកបានជួបជាមួយ មនុស្សជាច្រើន និងអរិយធម៌ ប្លែកៗ គ្នាជាច្រើនរបស់ប្រទេសទាំងនោះ ។

- លោកត្រឡប់មកទីក្រុងរ៉ូមវិញ ក្នុងឆ្នាំ៧៧មុនគ.ស ហើយចាប់ផ្តើមចូលប្រឡូកក្នុងអាជីពជាអ្នកនយោបាយ ជាមួយរដ្ឋបុរសម្នាក់ឈ្មោះ ប៉ុមប៊ី (ប៉ុមប៊ុ មហារាជ) ។

- ឆ្នាំ៧៤មុនគ.ស លោកបានចូលទៅធ្វើការនៅព្រឹទ្ធសភា ។ នៅទីនោះ លោកទទួលការគាំទ្រពីសំណាក់ពួកអភិជន ជាអ្នកមានទ្រព្យសម្បត្តិព្រមទាំងអ្នកមានអំណាចសំខាន់ៗ ជាច្រើន ក្នុងរបបអភិជនាធិបតេយ្យ ដើម្បីប្រកួតប្រជែងយកដំណែងជាកុងស៊ុលក្នុង


www.elibraryofcambodia.org

ឆ្នាំ៦៤មុនគ.ស ។ ប៉ុន្តែលោកត្រូវទទួលការមើលស្រាលពីសំណាក់គូប្រជែងរបស់លោក ម្នាក់ឈ្មោះ លុយស៊ីយូស សែកហ្សុស កាទីលីណា ។ លោកបានជាប់ឆ្នោត ប៉ុន្តែត្រូវបានកាទីលីណា និងបក្សពួករៀបចំអំពើក្បត់មួយ ដើម្បីផ្តួលរំលំរដ្ឋាភិបាល ។លោកបានកំចាត់ចោល (សម្លាប់) អ្នករួមគំនិតក្បត់ជាមួយ កាទីលីណា ។

- ពេលនោះក្រុមកៃសា និងព្រឹទ្ធសមាជិក បានយកលេសចោទប្រកាន់ថារូបលោកបានធ្វើការសំរេច ដោយប្រញាប់ប្រញាល់ពេកដោយមិនទុកឱ្យអ្នករួមគំនិតក្បត់ទាំងនោះ ត្រូវបានដំណើរការទៅតាមផ្លូវច្បាប់ ។

- ដោយហេតុថាលោក ប្រកែកមិនព្រមជានាជាមួយ ក្រុមកៃសា និង ក្រុមប៉ុមប៉ីក្នុងឆ្នាំ ៥៨មុនគ.ស លោកបានបង្ខំចិត្តនិរទេសខ្លួនទៅនៅម៉ាសេដូន ។ ប៉ុន្តែមួយឆ្នាំក្រោយមក លោកត្រូវបានប៉ុមប៉ុ អញ្ជើញឱ្យត្រឡប់ទេវិញ ។

- រហូតមកដល់ឆ្នាំ៥១មុនគ.ស លោកបានទទួលដំណែងជាកុងស៊ុល របស់ខេត្ត ប៉ុន្តែ លោកជាប់រវល់ច្រើនក្នុងការនិពន្ធសៀវភៅ ផ្នែកទស្សនវិជ្ជា ។

- ក្នុងឆ្នាំ៥០មុនគ.ស លោកបានចូលទៅធ្វើការជាមួយប៉ុមប៉ីដែលពេលនោះលោកក្លាយជាសត្រូវរបស់កៃសា ។ ក្រោយពីកៃសា


www.elibraryofcambodia.org

បានធ្វើឱ្យគូប្រឆាំងរបស់ខ្លួនបរាជ័យក្នុងឆ្នាំ៤៨មុនគ.ស ព្រមទាំងភៀសខ្លួនទៅកាន់អេហ្ស៊ីប ហើយត្រូវបានគេសម្លាប់នៅទីនោះ ។ លោកបានយល់យ៉ាងច្បាស់ថា ការប្រឆាំងបន្ថែមទៀត ទៅលើកៃសា នឹងមិនអាចនាំមកនូវក្តីសង្ឃឹមបានឡើយ ម្ល៉ោះហើយលោកក៏សុខចិត្ត យល់ព្រមចងសម្ព័ន្ធជាមួយកៃសា ។ គួរកត់សម្គាល់ផងដែរថា កៃសា បានក្លាយទៅជាជនផ្តាច់ការ ត្រួតត្រាតែម្នាក់ឯងទៅលើចក្រភព រ៉ូម ទាំងមូលក្នុងឆ្នាំ៤៥មុនគ.ស បន្ទាប់ពីយកជ័យជំនះលើ គណៈបក្សព្រឹទ្ធសភានៅអាហ្វ្រិកខាងជើង និង កំចាត់ចោលកូនប្រុសរបស់ប៉ុមប៉ី នៅប្រទេសអេស្ប៉ាញរួចមក។ ចំណែកលោកស៊ីសេរ៉ុង បានរស់នៅ ជាពលរដ្ឋធម្មតា ហើយបានបន្តការនិពន្ធរបស់លោក យ៉ាងពេញ ទំហឹង ។

- បន្ទាប់ពីកៃសា ត្រូវបានគេលបធ្វើឃាតដោយ ចាក់សម្លាប់ក្នុងមន្ទីរព្រឹទ្ធសភានោះមក លោកស៊ីសេរ៉ុង បានត្រឡប់មកកាន់ឆាកនយោបាយវិញ ដោយនឹកសង្ឃឹមថា សាធារណរដ្ឋនឹងត្រូវបានស្តាបនាឡើងវិញ ។ លោកបានជួយឧបត្ថម្ភចំពោះកូនចិញ្ចឹមរបស់លោកកៃសា ឈ្មោះ អុកតាវ (ក្រោយមក បានក្លាយ ទៅជាអធិរាជដ៏ល្បីល្បាញរបស់ចក្រភពរ៉ូម មានឈ្មោះថា អូហ្គុស) ។ ក្នុងការប្រយុទ្ធ ដើម្បីដណ្តើមអំណាចជាមួយកុងស៊ុលម្នាក់ឈ្មោះ


www.elibraryofcambodia.org

ម៉ាក់អង់ទ័ន ដែលជាឧត្តមសេនីយ៍ ។ ក្រោយមកអុកតាវ និងលោកម៉ាក់អង់ទ័ន បែរជាត្រូវរ៉ូវគ្នាជាមួយ អ្នកនយោបាយម្នាក់ទៀតឈ្មោះ លីពីឌូស ធ្វើជាដៃគូដើម្បីរៀបចំជាអង្គការទ្រីយ៉ូមវីរ៉ាតលើកទី II របស់ចក្រភពរ៉ូម ។ លោកត្រូវបង្ខំចិត្តនិរទេសខ្លួនជាលើកទីពីរ ប៉ុន្តែជាអកុសលលោកត្រូវបានបក្សពួករបស់ម៉ាក់អង់ទ័នសម្លាប់រូបលោក នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ៤៣ មុនគ.ស ។

## II. ស្នាដៃ

លោកបានសរសេរស្នាដៃជាច្រើនដូចជា : សេចក្តីអធិប្បាយអំពីសាធារណរដ្ឋ ច្បាប់ ភារកិច្ច ចរិតធម្មជាតិរបស់អាទិទេព និងសៀវភៅស្តីអំពីវាគ្មិន ។

## III. គំនិតនយោបាយសំខាន់ៗ

គំនិតនយោបាយរបស់លោក ទាក់ទងសំខាន់ទៅលើ ច្បាប់ចៅក្រម រដ្ឋ ទំរង់របស់រដ្ឋ និង អ្នកដឹកនាំរដ្ឋ ។

### ១-ច្បាប់

តាមគំនិតរបស់លោក**ច្បាប់** គឺជាការបែងចែករវាងអ្វីដែលត្រូវ និងអ្វីដែលខុស (Law is the distinction between things


www.elibraryofcambodia.org

just and unjust ) ដូច្នេះអ្វីដែលអាចឱ្យយើងបែងចែកបានរវាង អ្វីដែលត្រូវ និងអ្វីដែលខុសនោះគឺជាច្បាប់ ហើយអ្វីដែលអាចឱ្យ យើងដឹងបានថា អ្វី "ខុស" និងអ្វី "ត្រូវ" នោះគឺមានឈ្មោះថា "វិចារណញ្ញាណ" ។ លោកបានបន្តទៀតថាច្បាប់គឺជា វិចារណ ញ្ញាណត្រឹមត្រូវ (Law is the right reason) ហើយវិចារណ ញ្ញាណ ត្រឹមត្រូវនោះគឺជាកម្មសិទ្ធិរួមរបស់មនុស្ស និងអាទិទេព។ នៅពេលណា ដែលវិចារណញ្ញាណនោះក្លាយមកជាច្បាប់ យើង ជឿជាក់ថា មនុស្សនោះមានច្បាប់ ហើយអាទិទេពក៏មានច្បាប់ ដូចជា មនុស្សដែរ។

លោកបានផ្សារភ្ជាប់ ច្បាប់ទៅនឹងយុត្តិធម៌ ។ លោកបានលើក ឡើងថា អ្នកណាដែលបានចែករំលែកនូវច្បាប់ មានន័យថាអ្នកនោះ បានចែករំលែកនូវយុត្តិធម៌(Who share law must also share justice)។ លោកបានបែងចែកច្បាប់ជាពីរប្រភេទគឺ ច្បាប់ធម្មជាតិ និង ច្បាប់ដែលមិនទាន់មានលក្ខណៈជា លាយល័ក្ខអក្សរ ។ ច្បាប់ កើតមានតាំងពីមនុស្សមិនទាន់បង្រួបបង្រួមជា សង្គមមកម្ល៉េះ ។ ច្បាប់ជាសញ្ញា ឬជាសន្ធិសញ្ញាដំបូងរបស់រដ្ឋ ។


www.elibraryofcambodia.org

## ២-ចៅក្រម

ទាក់ទងទៅដល់ចៅក្រម លោកបានលើកឡើងថាចៅក្រមត្រូវមានមុខងារមួយគឺដឹកនាំគ្រប់គ្រង ផ្តល់នូវបទបញ្ជាត្រឹមត្រូវ ហើយមានផលកំរៃស្របទៅតាមច្បាប់ដែលបានចែង ។ ច្បាប់ជាអ្នកដឹកនាំ និង គ្រប់គ្រងចៅក្រម ហើយចៅក្រមដឹកនាំគ្រប់គ្រងមនុស្ស ។ ដូច្នេះច្បាប់ក៏ដឹកនាំគ្រប់គ្រងមនុស្សតាមរយៈចៅក្រមដែរ ។ ជីវិតរស់នៅរបស់មនុស្ស គឺជាកម្មវត្ថុនៃការចេញសេចក្តីសំរេចរបស់ច្បាប់ កំពូល (រដ្ឋធម្មនុញ្ញ) ។

លោកបានបញ្ជាក់ត្រង់ឃ្លាមួយថា ចៅក្រម គឺជាច្បាប់ចេះនិយាយ (Magistrate is a speaking law) ហើយច្បាប់គឺជាចៅក្រមដ៏ ស្ងៀមស្ងាត់ (Law is a silent magistrate) ។

## ៣-រដ្ឋ

តាមធម្មជាតិរដ្ឋកើតចេញពីគ្រួសារ ។ គ្រួសារជាកោសិការបស់សង្គម ហើយចេញពីសង្គមគ្រួសារគេទទួលបានរដ្ឋ ។ រដ្ឋគឺជាការប្រមូលផ្តុំមនុស្សដែលចងសម្ព័ន្ធភាព ដោយមានការឯកភាពគ្នាលើបញ្ហាច្បាប់ដែល ជាផលប្រយោជន៍រួមនៃពលរដ្ឋភាគច្រើន ។ ការបង្កើត ឬវីមួយឡើង មិនមែនជាព្រឹត្តិការណ៍ ដែលគេសន្មត


www.elibraryofcambodia.org

ឡើងនោះទេ ប៉ុន្តែវាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ គោលបំណង របស់រដ្ឋគឺ ធានាខុសត្រូវចំពោះសុភមង្គល របស់មនុស្សក្នុងបូរី ដោយភាពយុត្តិធម៌ បានន័យថាផ្តល់ចំពោះមនុស្សម្នាក់ៗនូវអ្វីដែល គេបានធ្វើចំពោះរដ្ឋ ។

## ៤-ទំរង់រដ្ឋ

លោកបានចែកទំរង់រដ្ឋជាបីប្រភេទគឺ រាជាធិបតេយ្យ អភិជនាធិបតេយ្យ និង ប្រជាធិបតេយ្យ ។ បើអំណាចកំពូលស្ថិតក្នុង កណ្តាប់ដៃ បុគ្គលម្នាក់គឺជា របបរាជាធិបតេយ្យ ។ បើអំណាច កំពូលស្ថិតនៅក្នុង កណ្តាប់ដៃមនុស្សមួយក្រុម ដែលសុទ្ធតែជា វរជនល្បីៗ នោះគេហៅថា របបអភិជនាធិបតេយ្យ ។ ពេលណា អំណាចកំពូលស្ថិតនៅ ក្នុងកណ្តាប់ដៃរបស់ប្រជាជនទាំងមូល គេហៅថា របបប្រជាធិបតេយ្យ ។ លោកបានគូសបញ្ជាក់ថា ទំរង់រដ្ឋដែលល្អជាងគេគឺ របបរាជាធិបតេយ្យ ប៉ុន្តែរដ្ឋ ដែលសុក្រិត ជាងគេបំផុត គឺទំរង់រដ្ឋ ដែលបញ្ចូលគ្នាដោយរបបទាំងបីហើយ បង្កើតជាទំរង់ថ្មីមួយ ដែលលោកហៅថា សាធារណរដ្ឋបែប អភិជនាធិបតេយ្យអាស្រ័យសភា ពីព្រោះទំរង់របៀបនេះអាចធានា ឱ្យបូរីមានភាពស្រុះស្រួលគ្នា ។ លោកមិនពេញចិត្តនឹងរបបយោធា និយមផ្តាច់ការឡើយ ។


www.elibraryofcambodia.org

## ៥-នយោបាយ

លោកបានផ្ដល់គំនិតថា  នយោបាយត្រូវខ្ពស់ជាងសីលធម៌ ។ លោក ប្រៀបធៀបនយោបាយទៅនឹងវិទ្យាសាស្ត្រទូទៅមួយហើយ សីលធម៌ ជាវិទ្យាសាស្ត្រដោយឡែក ។ ជានិច្ចកាល វិទ្យាសាស្ត្រ ទូទៅតែងខ្ពស់ ជាងវិទ្យាសាស្ត្រដោយឡែក ។

## ៦-អ្នកដឹកនាំរដ្ឋ

តាមគំនិតរបស់លោក  អ្នកដឹកនាំរដ្ឋគប្បីជាមនុស្សដែលមាន ភាពឆ្លាតវៃមានគតិបណ្ឌិត មានយុត្តិធម៌មានពាក្យសំដីគួរឱ្យកក់ក្ដៅ ហើយ បានឆ្លងកាត់ការរៀនសូត្រលើមុខវិជ្ជាស្ដីពីច្បាប់ និងរដ្ឋ ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកសាំងអូហ្គូស្តាំង

## ៣៥៤-៤៣០ គ.ស

### I .ជីវិតនិងបុគ្គលិកលក្ខណៈ



- លោកកើតនៅថ្ងៃទី១៣-១១-៣៥៤ ក្នុងទីក្រុងមួយមានឈ្មោះ តាហ្គាសនុយមីដ្យា សព្វថ្ងៃឈ្មោះថា ស៊ុក អារ៉ាស នៃ ប្រទេសអាល់ហ្សេរី ។

- ឪពុកឈ្មោះ ប៉ាទ្រីស្យូស

- ម្តាយឈ្មោះ ម៉ូនីកា

- លោកជាទស្សនវិទូគ្រីស្ត សាសនា ។

- លោកបានរៀនសូត្រផ្នែកវោហារសាស្ត្រ ហើយត្រូវបានគេចាត់ទុកថា ជាអ្នកវោហារសាស្ត្រក្នុងទីក្រុងទាំងឡាយនៃភាគខាងជើង របស់អាហ្វ្រិកដូចជា តាហ្គាស ម៉ាដូរ៉ា និងកាតាស្ស ។ លោកបានបង្រៀនមុខវិជ្ជានេះនៅទីក្រុងដទៃទៀត ដូចជា ក្រុងរ៉ូម


www.elibraryofcambodia.org

កាតាស្ស និង មីឡង់ ។

- ក្នុងឆ្នាំ៣៧២ លោកបានរួមរស់ជាមួយស្ត្រីម្នាក់ រហូតដល់មានកូនមួយឈ្មោះអាដេអូដូទូស មានន័យថាអំណោយអាទិទេព ។

- លោកបានទទួលឥទ្ធិពល ពីវាគ្មិនដ៏ល្បីៗ ដូចជា លោកស៊ីសេរ៉ុង ជាដើម ។ លោកបានកំណត់ថា មុននឹងក្លាយទៅជាគ្រីស្តសាសនិក គេត្រូវការចំណេះដឹង និង បទពិសោធន៍ខាងផ្នែកទស្សនវិជ្ជា ។

- ក្នុងឆ្នាំ៣៨៣ លោកបានចេញពីកាតាស្ស ទៅរស់នៅទីក្រុងរ៉ូម ប៉ុន្តែមួយឆ្នាំក្រោយមកគឺនៅឆ្នាំ៣៨៤ លោកបានធ្វើដំណើរទៅកាន់ទីក្រុងមីឡង់ ហើយបន្តបង្ហាត់បង្រៀនមុខវិជ្ជាផ្នែក វោហារសាស្ត្រនេះ តទៅទៀត ។

- លោកបានជួបជាមួយសង្ឃកាតូលិក នៅទីក្រុងមីឡង់ឈ្មោះអមប្រូស្ស ព្រមទាំងជួបជាមួយសង្ឃកាតូលិកល្បីៗ ជាច្រើននៃប្រទេសអ៊ីតាលី ។ ការជួបជាមួយសង្ឃកាតូលិកទាំងអស់នោះបានធ្វើឱ្យលោកមានការជាប់ចិត្តយ៉ាងខ្លាំងជាមួយសាសនាគ្រីស្ត ។

- លោកបានបួសជាសង្ឃកាតូលិកនៅអ៊ីតាលីក្នុងឆ្នាំ៣៨៧ ។



www.elibraryofcambodia.org

## II. ស្នាដៃ

លោកបាននិពន្ធស្នាដៃជាច្រើនដូចជា "បូរីអាទិទេព"(City of God) ដែលមានចំនួន២២ក្បាល ក្នុងចន្លោះឆ្នាំ៤១៣_៤២៦ ។ បន្ទាប់មកទៀត គឺសៀវភៅឈ្មោះ "ហ្វ្រីវិល" ( Free Will ) ចាប់ពីឆ្នាំ (៣៨៨ ដល់ ៤២៩) ។ ស្នាដៃមួយទៀតឈ្មោះថា "គ្រីស្ទៀនដុកទ្រីន" (Christian Doctrine)(៣៩៧) ។ ស្នាដៃចុងក្រោយរបស់លោកគឺ "ណេឆ័រ អេនក្រេស" ( Nature and Grace) (៤១៥) ។

លោកទទួលមរណភាពនៅថ្ងៃទី២៨ សីហា ឆ្នាំ៤៣០ នៅ អ៊ីប៉ូ ជាកំពង់ផែទំនើបមួយរបស់អាល់ហ្សេរី ជាទីកន្លែងដែលលោកបានក្លាយជា មេដឹកនាំវិហារកាតូលិកតាំងពីឆ្នាំ៣៩៤ ។

## III. គំនិតនយោបាយសំខាន់ៗ

### ១-សន្តិភាព

តាមគំនិតរបស់លោក សន្តិភាពត្រូវផ្សារភ្ជាប់ជាមួយយុត្តិធម៌។ សន្តិភាពមិនអាចកើតមានបានទេបើសិនជាគ្មានយុត្តិធម៌។ សន្តិភាពគឺជាលក្ខខ័ណ្ឌទីមួយ នៃគោលបំណងរបស់ព្រះមហាក្សត្រ ឬ អ្នកដែល មានឋានៈខ្ពស់បំផុត ។ បើមានសន្តិភាពគេអាចឆ្ពោះទៅរក



www.elibraryofcambodia.org

ភាពស្រុះស្រួលគ្នា ភាពស៊ីសង្វាក់គ្នារវាងអ្នកដឹកនាំ និងអ្នកត្រូវគេដឹកនាំហើយ សំខាន់បំផុតគឺការយល់ព្រមពីសំណាក់អ្នកនៅក្រោមបង្គាប់ ។ សន្តិភាពរបស់បូរីគឺជា ភាពស្រុះស្រួលគ្នាប្រកបដោយសណ្តាប់ធ្នាប់ នៃអ្នកបញ្ជា និងអ្នកដែលគោរពតាមបញ្ជា ។

## ២-រដ្ឋ

រដ្ឋ ជាអ្នកផ្តល់នូវសន្តិភាព សំរាប់សង្គម ។ រដ្ឋគឺជាការប្រមូលផ្តុំ របស់គ្រួសារ ។

រដ្ឋត្រូវគិតគូរអំពីយុត្តិធម៌ទើបរដ្ឋមានសន្តិភាព ។

រដ្ឋដែលមិនគិតគូរអំពីយុត្តិធម៌នោះគឺជារដ្ឋឆក់ប្លន់ ។

## ៣-យុត្តិធម៌

យុត្តិធម៌ត្រូវឋិតនៅពីលើ និង ខ្ពស់ជាងបណ្តាទំរង់ទាំងឡាយនៃអំណាច ។

យុត្តិធម៌ ត្រូវតែបានជ្រួតជ្រាបទៅក្នុង សកម្មភាពរបស់អ្នកដឹកនាំ។ តើវាជាណាចក្រទាំងអស់ នឹងទៅជាយ៉ាងណា បើសិនជាគ្មានយុត្តិធម៌សោះនោះ ។ បើគ្មានយុត្តិធម៌ វាជាណាចក្រទាំងអស់នោះនឹងក្លាយទៅជាកន្លែងប្រព្រឹត្តអំពើឆក់ប្លន់ដ៏ធំមួយ ។


www.elibraryofcambodia.org

ទាក់ទងទៅនឹងយុត្តិធម៌ព្រហ្មទណ្ឌ លោកបានរារាំងមិនឱ្យមានការធ្វើទុក្ខទោសរហូតដល់ស្លាប់ ឬ ធ្វើទារុណកម្មបែបណាមួយទៅលើ រូបរាងកាយរបស់មនុស្ស ។

លោកបានផ្សារភ្ជាប់យុត្តិធម៌ទៅនឹងសង្គ្រាម ។ សង្គ្រាមអាចជា អំពើយុត្តិធម៌ប្រសិនបើសង្គ្រាម ជាសង្គ្រាមដើម្បីធ្វើឱ្យបុរីរស់រាន ។ ប៉ុន្តែលោកស្នើសុំឱ្យបញ្ឈប់នូវសង្គ្រាម ដែលមានលក្ខណៈជាការ ច្បាំងដណ្តើម ។

## ៤-អំណាច

ក្នុងគ្រួសារ អំណាចត្រូវឋិតក្នុងកណ្តាប់ដៃរបស់ឪពុកដែលមានលក្ខណៈស្វាហាប់បំផុត ។ ក្នុងបុរីឬចក្រភព គំរូនៃអំណាចត្រូវឋិតនៅក្នុងកណ្តាប់ដៃសម្តេច ឬអធិរាជ ។ ប៉ុន្តែសម្តេច ឬ អធិរាជមិនមែនជា ម្ចាស់នៃអំណាចទេ ផ្ទុយទៅវិញជាអ្នកទទួលរក្សាទុកនូវអំណាចនេះ។

ក្រសួង ជាអ្នកបំរើចំពោះបុរី ឬ ចំពោះចក្រភពទាំងមូល ។

ក្រសួង មានករណីយកិច្ចបំរើអ្វីដែលជាផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។ ក្រសួងជាអ្នកបញ្ជា ឬបំភ្លឺការពិតចំពោះ ប្រជាពលរដ្ឋ ហើយធ្វើយ៉ាងណាឱ្យមានយុត្តិធម៌ចំពោះប្រជាពលរដ្ឋទូទៅ ។



www.elibraryofcambodia.org

អំណាចកើតចេញពីឆន្ទៈ របស់អាទិទេព ។ អាទិទេពបាន កំណត់ រួចជាស្រេចនូវអ្នកដែលដឹកនាំនិងអ្នកដែលឋិតនៅក្រោម ការដឹកនាំ។

គោលបំណងរបស់អំណាចគឺផ្តល់ យុត្តិធម៌ សន្តិភាព និង ការឯកភាព រវាង អ្នកដែលដឹកនាំ និង អ្នកដែលឋិតនៅក្រោម ការដឹកនាំ។

អំណាចមានពីរប្រភេទគឺ អំណាចសាសនចក្រ (អំណាចខាង សាសនា) និង អំណាចអាណាចក្រ ។ អំណាចទាំងពីរ ត្រូវជួយគ្នា ទៅវិញទៅមក ។ រដ្ឋត្រូវជួយការពារព្រះវិហារ ឱ្យចាកផុតពីសត្រូវ ទាំងឡាយដោយប្រើកំលាំងអាវុធ ។ ប៉ុន្តែ ព្រះវិហារក៏ត្រូវជួយរដ្ឋ វិញដែរ ដោយជួយអប់រំស្មារតីប្រជាពលរដ្ឋទាំងអស់តាមរយៈគម្ពីរ របស់ សាសនា ។

លោកបានឱ្យតម្លៃទៅលើអំណាចព្រះវិហារថាជាអំណាចខ្ពស់ បំផុត ។ សម្តេចប៉ាបគ្រប់គ្រងព្រះវិហារហើយមានភារកិច្ច ត្រួត ពិនិត្យ មើលអំណាចរបស់អាណាចក្រ ។ អ្វីៗ ទាំងអស់នៅលើ ផែនដីសុទ្ធតែ ឋិតក្រោមការរៀបរយរបស់អាទិទេពទាំងអស់ ។


www.elibraryofcambodia.org

## ៥-តួនាទីរបស់ច្បាប់

ច្បាប់របស់មនុស្ស តែងផ្អែកលើច្បាប់របស់អាទិទេពដែលមានលក្ខណៈអមតៈ ។

មនុស្សត្រូវតែ គោរព យល់ពីច្បាប់ និង ស្រឡាញ់ ច្បាប់ ។ លោកបាន ទទួលស្គាល់ថាមានច្បាប់អយុត្តិធម៌ ដែលប្រឆាំងនឹងអាទិទេពហើយ ក៏មានច្បាប់អាក្រក់អាចក្លាយជាច្បាប់ល្អបានដែរ ។

## ៦-សេចក្ដីស្នេហា

សេចក្ដីស្នេហាប្រកបដោយការលះបង់ គឺជាសេចក្ដីស្នេហាដែល មានតួនាទីនយោបាយហើយឋិតក្នុងការបញ្ជារបស់អ្នកដឹកនាំនិងការគោរពរបស់អ្នកដែលឋិតក្រោមការដឹកនាំ ។ សេចក្ដីស្នេហាបែបនេះ អាចធានាឱ្យមានការឯកភាពប្រជាពលរដ្ឋនៅក្នុងបូរី ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកសាំងតូម៉ាស់ដាកាំង

## ១២២៥-១២៧៤ គ.ស

## (Saint Thomas d'Aquin)

### I. ជីវិតនិងបុគ្គលិកលក្ខណៈ




- លោកបានកើតនៅទីក្រុងរ៉ូកាសិកកា ដែលស្ថិតនៅចន្លោះ ទីក្រុងរ៉ូម និង ទីក្រុងណាប់ ។

- អាយុបាន១៨ឆ្នាំលោកបានទៅសិក្សានៅ ទីក្រុងណាប់ កូឡូញ និង ប៉ារីស ។ នៅទីក្រុងប៉ារីសលោកត្រូវបានគេស្រឡាញ់ និងរាប់អានច្រើន ដោយសារលោកជានិស្សិតរៀនពូកែ បន្ទាប់មក លោកបានក្លាយទៅជាគ្រូបង្ហាត់ផ្នែកទេវវិទ្យា និង ទស្សនវិជ្ជា ។

- លោកបានរួមដំណើរជាមួយលោក សាំងអូហ្គូស្តាំង អភិវឌ្ឍទ្រឹស្តីផ្នែកសាសនា ។


www.elibraryofcambodia.org

- លោកជាមនុស្សមានចិត្តសប្បុរស មានសទ្ធាជ្រះថ្លា សុភាពរាបសា មានចិត្តជាកណ្តាលនិងបរិសុទ្ធ ។

- លោកបានទទួលឥទ្ធិពល ពីលោកអារីស្តុត ប៉ុន្តែលោកបានខិតខំសំរបសំរួល រវាងអ្វី ដែលជាលក្ខណៈអារីស្តូតនិយម និងគ្រីស្តនិយម ។

- លោកជាអ្នកផ្តើមគំនិតបង្កើត នូវ នីតិរដ្ឋ ។

## II.គំនិតនយោបាយសំខាន់ៗ

### ១-ការរៀបចំបូរី

ការរៀបចំបូរីត្រូវឋិតនៅលើរចនាសម្ព័ន្ធមួយដែលមានលក្ខណៈជាលំដាប់ថ្នាក់ ។ មូលដ្ឋានគ្រឹះនៃការរៀបចំបូរី ជាបឋមត្រូវឋិតនៅ លើការរៀបចំគ្រួសារ បន្ទាប់មកគឺបូរី ហើយជាចុងក្រោយគឺរាជាណាចក្រ ។

ការរៀបចំបូរីត្រូវឋិតនៅលើការងារ ។ ការងារត្រូវរៀបចំទៅតាមតម្លៃនៃបៀវត្សត្រឹមត្រូវ ។ របស់របរដែលផលិតបានត្រូវលក់ ទៅតាមតម្លៃត្រឹមត្រូវហើយទទួលបាននូវកំរៃត្រឹមត្រូវ ។

### ២-ការដឹកនាំបូរី

បទដ្ឋានសំខាន់នៃការដឹកនាំបូរីគឺគុណធម៌រួម ដែលបានកត់ត្រា


www.elibraryofcambodia.org

ក្នុងច្បាប់អាទិទេព និង ច្បាប់ធម្មជាតិ ។ ការដឹកនាំបូរីមិនមែនឋិតលើបុព្វសិទ្ធិនៃអំណាច សាធារណៈនោះទេ ប៉ុន្តែត្រូវឋិតនៅលើបេសកកម្ម នៃសេវាកម្មសាធារណៈ ។

• **អំណាចនីតិបញ្ញត្តិ**

គឺជាអំណាចមួយដែលខ្ពស់បំផុត ដែលឃុំគ្រងដោយ សហគមន៍មនុស្ស ។ សហគមន៍មនុស្សគឺជា សហគមន៍តែមួយគត់ដែលបាន កំណត់នូវគុណធម៌រួម ទោះបីជាគុណធម៌នោះ ចេញពីអាទិទេព ក៏ដោយ ។ លោកបានលើកឡើងនូវទ្រឹស្តី ស្តីអំពីអធិបតេយ្យដំបូង របស់ប្រជាជនតាមរយៈរូបមន្តមួយឃ្លាថា "អំណាចចេញពីអាទិទេព តែដោយសារប្រជាជន" ។

• **តួនាទីរបស់រដ្ឋាភិបាល**

បើគេចាត់ទុកបូរីជាអង្គឯកភាពមួយនៃចំនួនដ៏ច្រើន ហើយរដ្ឋាភិបាល គឺជាគោលការណ៍ដឹកនាំ នៃពហុភាពដែលឋិតក្នុងភាពស្របគ្នានៃច្បាប់ ធម្មជាតិ និង ច្បាប់អមតៈ ។ រដ្ឋាភិបាលដែលត្រឹមត្រូវ គឺជារដ្ឋាភិបាល ដែលបានកើតឡើងដោយឈរនៅលើគុណធម៌រួម។ ផ្ទុយទៅវិញរដ្ឋាភិបាលដែលមិនត្រឹមត្រូវ គឺជា រដ្ឋាភិបាលដែលបង្កើតឡើងដោយឈរលើផលប្រយោជន៍ផ្ទាល់ខ្លួន ។



www.elibraryofcambodia.org

ប្រសិនបើ ព្រះរាជាធ្វើអ្វីហួសពីអំណាចរបស់ខ្លួននោះ ប្រជារាស្ត្រអាចនឹងបះបោរប្រឆាំង ។

• **រូបភាពរដ្ឋាភិបាល**

លោកបានឯកភាពទៅនឹងគំនិតរបស់លោកអារីស្តូត ដែលបានបែងចែករូបភាពនៃរដ្ឋាភិបាលជាបី និងការប្រែប្រួលបន្តិចម្តងៗ នៃរូបភាពទាំងបីនោះ ។ រដ្ឋាភិបាលត្រូវមានរូបភាពបីគឺ រាជាធិបតេយ្យ អភិជនាធិបតេយ្យ និង រដ្ឋាភិបាលប្រជាមានិតុ (រដ្ឋាភិបាល ប្រជាធិបតេយ្យ) ។ របបដែលសក្តិសមបំផុតនោះគឺរបបចំរុះ រវាង របបរាជាធិបតេយ្យ អភិជនាធិបតេយ្យ និង ប្រជាធិបតេយ្យដែលអាចឱ្យចៀសវាងបាន នូវការរំលោភគ្រប់បែបយ៉ាងពីរូបភាពនៃអំណាច នីមួយៗ ។ ហេតុដូច្នេះហើយ រូបលោកត្រូវបានចាត់ទុកថាជាអ្នកផ្តួចផ្តើមគំនិតទៅលើការបែងចែកអំណាច ។

## ៣-ច្បាប់

លោកបានបែងចែកច្បាប់ជាបីប្រភេទគឺ :

**ក.ច្បាប់អមតៈ :** ដែលគ្របដណ្តប់ទៅលើច្បាប់ផ្សេងទៀត ។ ច្បាប់អមតៈតំណាងឱ្យ វិចារណញ្ញាណ អាទិទេពដែលគ្រប់គ្រងដឹកនាំ ពិភពលោកទាំងមូល ។



www.elibraryofcambodia.org

**ខ.ច្បាប់ធម្មជាតិ :** ច្បាប់ទាំងនេះទាក់ទងទៅនឹង វិចារណញ្ញាណរបស់មនុស្ស ។ ច្បាប់ធម្មជាតិចែកចេញជាពីរផ្នែក គឺ ច្បាប់ធម្មជាតិដំបូង និង ច្បាប់ធម្មជាតិបន្ទាប់បន្សំ ។

- ច្បាប់ធម្មជាតិដំបូង ជាច្បាប់ធម្មជាតិមិនប្រែប្រួល ។ ច្បាប់នេះ នាំទៅដល់គោលការណ៍មួយគឺ ប្រព្រឹត្តអំពើល្អ ចៀសវាងអំពើអាក្រក់ ។

- ច្បាប់ធម្មជាតិបន្ទាប់បន្សំ ប្រែប្រួលទៅតាមប្រទេសនីមួយៗ ហើយជាចុងក្រោយច្បាប់នេះត្រឡប់មករកច្បាប់របស់មនុស្សវិញ។

**គ.ច្បាប់របស់មនុស្ស :** គឺជាស្នាដៃនៃវិចារណញ្ញាណរបស់មនុស្ស ដែលបង្កើតបានជាវិធានអនុវត្តក្នុងជីវភាពសង្គម ។ ច្បាប់គឺជាសេចក្ដីបង្គាប់របស់វិចារណញ្ញាណ ដោយនាំមកនូវ គុណធម៌ទូទៅ ។ ច្បាប់ត្រូវបានតាក់តែងឡើង និងប្រកាសឱ្យប្រើដោយអ្នកដឹកនាំបូរី ។ ដូច្នេះច្បាប់ដែលត្រូវបានអនុម័តជាទៀងទាត់ដោយសហគមន៍ត្រូវតែ ទទួលបាននូវការគោរព ។ ជារួមច្បាប់ត្រូវមានចរិតលក្ខណៈសំខាន់ៗ ចំនួនបី គឺ :

- ច្បាប់ត្រូវអនុម័តទៅតាមវិធានមួយចំនួនរបស់វិចារណញ្ញាណ
- ច្បាប់ត្រូវតែត្រឹមត្រូវនិងស៊ីសង្វាក់គ្នាជារួមជាមួយនឹងអំពើល្អ
- ច្បាប់ត្រូវមានធម្មានុរូបភាព



www.elibraryofcambodia.org

## ៤-រដ្ឋ

រដ្ឋ គឺជាផ្នែកមួយនៃការរៀបចំពិភពលោក ឱ្យមានសណ្តាប់ធ្នាប់ របស់អាទិទេព ។ រដ្ឋកើតចេញពីការប្រមូលផ្តុំគ្នានៃក្រុមមនុស្សក្នុង សង្គមនយោបាយ ។

រដ្ឋដែលកើតឡើង គឺជាលទ្ធផលនៃទំនោរធម្មជាតិរបស់មនុស្សឆ្ពោះទៅរកការរួមរស់ជាមួយគ្នា ។

គោលបំណងរបស់រដ្ឋ គឺផលប្រយោជន៍រួម ទាំងសំភារៈ និងស្មារតី ហើយស្មារតីមានសារៈសំខាន់បំផុត ។ ប៉ុន្តែលោកក៏អះអាងផងដែរថា ការផ្គត់ផ្គង់ផ្នែកសំភារៈសំរាប់សមាជិកសង្គមទាំងអស់ក៏មានសារៈសំខាន់ផងដែរ ព្រោះវាអាចជួយជំរុញឱ្យ ការរស់នៅរបស់មនុស្ស ប្រកបដោយគុណធម៌ ។

ចំពោះទំរង់រដ្ឋវិញ លោកបានឯកភាពទាំងស្រុងទៅតាមគំនិតរបស់លោកអារីស្តូត ដែលបែងចែករដ្ឋជាទំរង់ពីរគឺ ទំរង់រដ្ឋបរិសុទ្ធ និង មិនបរិសុទ្ធ ។ លោកបានហៅទំរង់រដ្ឋទាំងនោះជា ទំរង់រដ្ឋត្រឹមត្រូវ និង មិនត្រឹមត្រូវ ។

- ទំរង់រដ្ឋត្រឹមត្រូវមានអំណាចនយោបាយ ហើយអំណាចនយោបាយនោះនាំមកនូវភាពសម្បូណ៌សប្បាយជូនប្រជាពលរដ្ឋ ។



www.elibraryofcambodia.org

ទំរង់រដ្ឋត្រឹមត្រូវ ឈរលើមូលដ្ឋាន នៃការគោរពច្បាប់ និង ប្រពៃណី ។

- ទំរង់រដ្ឋមិនត្រឹមត្រូវគឺមានតែអំណាចផ្តាច់ការតែប៉ុណ្ណោះ ។ ទំរង់រដ្ឋមិនត្រឹមត្រូវគឺធ្វើអ្វីៗ ទៅតាមតែទំនើងចិត្ត ជារដ្ឋដែលមិនកំណត់ឡើងដោយច្បាប់ឡើយ ។

ក្នុងទំនាក់ទំនងរវាងរដ្ឋ និង ព្រះវិហារវិញ លោកបាន លើកឡើង ថាអំណាចព្រះវិហារជាអំណាចកំពូល ។ សម្តេចប៉ាបជាអ្នកមានអំណាច គ្រប់គ្រងទៅលើ ស្តេចទាំងឡាយហើយមានសិទ្ធិធ្វើអន្តរាគមន៍ ទៅលើការដឹកនាំរបស់ស្តេចនៃបណ្តាប្រទេសនីមួយៗ ទៀតផង ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកម៉ាគីយ៉ាវែល

## ១៤៦៩_១៥២៧

## ( Machiavel )

### I .ជីវិតនិងចរិតលក្ខណៈ



- លោកជាជនជាតិអ៊ីតាលី ។ លោកកើតនៅថ្ងៃទី០៨/៥/១៤៦៩ នៅបុរីឈ្មោះហ្វ្លរ៉ង់(Florence) ។

- លោកបានកើតក្នុងស្ថានភាពមួយដែលប្រទេសអ៊ីតាលី ត្រូវបែងចែកជានគរតូចៗជាច្រើន ដែលពោរពេញទៅដោយការច្បាំងដណ្តើម អំណាចគ្នាហើយខ្វះការឯកភាពគ្នា ។



www.elibraryofcambodia.org

- លោកត្រូវបានគេចាត់ទុកថា ជាទស្សនវិទូនយោបាយ ជាប្រវត្តិវិទូ និង ជាអ្នកទ្រឹស្តីខាងសង្គ្រាម ហើយក៏ជាស្ថាបនិកខាងផ្នែកប្រវត្តិសាស្ត្រនយោបាយ តាមរយៈការអង្កេតដោយផ្ទាល់ ឬតាមរយៈ ការអានដ៏ច្រើនសន្ធឹកសន្ធាប់របស់លោក ។

- លោកជាមនុស្សម្នាក់ដែលរស់នៅដើម្បីបុព្វហេតុនៃការ ឯកភាពរបស់ប្រទេសអ៊ីតាលី ។ លោកបានអះអាង តាមរយៈសំដីដ៏រឹងមាំដាច់ណាត់ថា " បើគ្មានសម្តេចគឺគ្មានការឯកភាព " ។

- លោកត្រូវបានគេទទួលស្គាល់ថាជាអ្នកការទូតប្រចាំនៅបណ្តាប្រទេសជាច្រើន ហើយមានតួនាទីជាអ្នកនាំពាក្យទៅកាន់វិមានទាំងឡាយដូចជាវិមាន សម្តេចប៉ាប ស្តេចបារាំង វិមានអធិរាជអាល្លឺម៉ង់ ក៏ដូចជា ទៅកាន់រដ្ឋាភិបាលអ៊ីតាលីផងដែរ ។

- តាំងពីកុមារមក លោកបានខិតខំរៀនសូត្រភាសាក្រិក និងភាសាឡាតាំង ។

- អាយុបាន៩ឆ្នាំ លោកបានឃើញផ្ទាល់ភ្នែកនូវសោកនាដកម្ម និងការសម្លាប់រង្គាល ទៅលើពួក Pazzi ដែលចង់ធ្វើគុតស្តេចមួយអង្គឈ្មោះ ឡូរង់ដឺមេឌីស៊ីស (Laurent de Médecis) ។

- អាយុបាន២៥ឆ្នាំ លោកបានជួបស្តេចបារាំង ឈ្មោះហ្សាល់ទី៨ (Charles VIII) ដែលពេលនោះបានយាងទៅដល់ហ្វ្លរ៉ង់ ។


www.elibraryofcambodia.org

-ជាមួយគ្នានេះដែរនៅហ្វ្លរ៉ង់ កើតមានព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយ ។ មេដឹកនាំសាសនាមួយរូបឈ្មោះ ហ្សេរ៉ូមសាវ៉ូណារ៉ូល (Jérôme Savonarole) បានដឹកនាំមហាជនប្រឆាំងនឹងសម្តេចប៉ាប(ស្តេចសង្ឃកាតូលិក) របស់ហ្វ្លរ៉ង់ ព្រមទាំងបានធ្វើការប្រឆាំងនឹងស្តេចមួយអង្គឈ្មោះ អាឡិចហ្សង់ទី៦ប័រហ្សីយ៉ា (AlexandreVI Borgia) ។ ចលនានេះ ត្រូវបានបង្ក្រាបយ៉ាងសាហាវហើយលោកហ្សេរ៉ូមសាវ៉ូណារ៉ូល ត្រូវបានគេចាប់យកទៅកាត់ទោសប្រហារជីវិតដោយកាត់ក្បាល ដោយស្តេចអាឡិច ហ្សង់ នៅលើទីលានមួយមានឈ្មោះ ថា សែងញ៉ឺរីយ៉ា (Seigneuria) ក្នុង ថ្ងៃ ទី២៣ ខែ ឧសភា ឆ្នាំ១៤៩៨ ហើយលោកបានឃើញផ្ទាល់ភ្នែកចំពោះព្រឹត្តិការណ៍ ដ៏គួរឱ្យរន្ធត់នេះ ។

- លោកជាមនុស្សម្នាក់ដែលចូលចិត្តភាពឆើតឆាយ (ទាំងរបស់របរក៏ដូចជាមនុស្ស) លោកចូលចិត្តស្ត្រីដែលមានសម្រស់ឆើតឆាយ និងចូលចិត្តបរិភោគអាហារដែលឆ្ងាញ់ៗ ។

- លោកជាមនុស្សប្រកបដោយកលល្បិចច្រើន និងចូលចិត្តការសប្បាយ ។

- លោកមានចំណូលចិត្តទៅលើការអានសៀវភៅ ។

- លោកជាមនុស្សស្រឡាញ់អំណាច ។


www.elibraryofcambodia.org

- លោកមិនសូវចូលចិត្តឱ្យតម្លៃទៅលើអ្វី ដែលមានលក្ខណៈសីលធម៌ប៉ុន្មានទេ ទាំងក្នុងជីវភាពរស់នៅ ក៏ដូចជានៅក្នុងទស្សនៈនយោបាយ ។ គំនិតដ៏ល្បីល្បាញរបស់លោកគឺ បំបែកបំបាក់ដើម្បីត្រួតត្រា ។

- ក្នុងជីវភាពរបស់លោក លោកបានចូលរួមក្នុង គណៈកម្មាធិការមួយឈ្មោះ Commission des Dix pour la liberté et la paix របស់លោក Pierre Soderini ដែលធាតុពិតគឺជាគណៈកម្មាធិការមានទ្រង់ទ្រាយជា ក្រសួងមហាផ្ទៃ និង សង្គ្រាម (Ministère de l'intérieur et de la guerre ) ។ ដោយការចូលរួមនេះ លោកត្រូវគេចោទប្រកាន់ថា បានរួមគំនិតក្បត់ (Conspirateur) បន្ទាប់ពីការយាងត្រឡប់របស់ស្តេច ឡូរ៉ង់ដឺម៉េឌីស៊ីស ។

- លោកត្រូវបានគេដាក់ឱ្យចូលនិវត្តន៍ទាំងបង្ខំព្រមទាំងនិរទេសឱ្យទៅនៅភូមិកំណើតរបស់លោក ។ លោកបានទទួលមរណភាពនៅហ្វូរ៉ង់ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៥២៧ ។

## II. ស្នាដៃ

- ក្នុងការស្នាក់អាស្រ័យនៅភូមិកំណើត លោកបាននិពន្ធស្នាដៃមួយឈ្មោះ"សុន្ទរកថាស្តីពីការកែប្រែរដ្ឋហ្វូរ៉ង់" នៅឆ្នាំ១៥២១ ។


www.elibraryofcambodia.org

- ស្នាដៃនោះបានធ្វើឱ្យព្រះរាជាលើកលែងទោស ព្រមទាំងប្រគល់ភារកិច្ចឱ្យលោកសរសេរបន្ថែមទៀត អំពីប្រវត្តិសាស្ត្ររបស់ហ្វូរ៉ង់ (ពីឆ្នាំ ១៥២០-១៥២៥) ។

-លោកបាននិពន្ធស្នាដៃដ៏ល្បីល្បាញមួយទៀតឈ្មោះ "សម្តេច" ក្នុងឆ្នាំ១៥១៣-១៥១៤ ដើម្បីយកទៅថ្វាយព្រះចៅ Médecis ហើយសុំការងារធ្វើពីព្រះអង្គ ក្នុងឱកាសរាត្រីសមោសរមួយ ។ ដោយសារឱកាសមិនអំណោយផលបែបនេះ ព្រះរាជាមិនជាចាប់អារម្មណ៍ប៉ុន្មានឡើយ។ ដើម្បីជាកិច្ចថ្លែងអំណរគុណ ព្រះអង្គគ្រាន់តែជូនស្រាពីរដបដើម្បីទុកជាចំណងដៃ និងសេចក្តីថ្លែងអំណរគុណរបស់ព្រះអង្គ ។ ដូចនេះលោកមិនបានសំរេចនូវគោលបំណងដើម្បីសុំការងារធ្វើជាថ្នូរចំពោះស្នាដៃរបស់លោកនោះឡើយ ។ ក្រោយមក គឺនៅឆ្នាំ១៥១៥ ទើបស្នាដៃនេះត្រូវបានគេយកទៅ បោះពុម្ពផ្សាយជាសាធារណៈដោយមិត្តភក្តិរបស់លោក ដែលបានឱ្យតំលៃថាជាស្នាដៃមានតម្លៃប្រវត្តិសាស្ត្រនិងអក្សរសិល្ប៍ដ៏ជ្រាលជ្រៅបំផុត។

- ស្នាដៃរបស់លោកមួយទៀតគឺ "សិល្បៈនៃសង្គ្រាម" ។

## III. គំនិតនយោបាយសំខាន់ៗ

### ១-គំនិតនយោបាយស្តីពី "រដ្ឋ"



www.elibraryofcambodia.org

- កម្មវត្ថុនៃការសិក្សារបស់លោកគឺ "រដ្ឋ" ។ លោកបានប្រើពាក្យ "រដ្ឋ" នៅដើមបន្ទាត់ទីមួយនៃស្នាដៃរបស់លោក ដែលមានឈ្មោះ"សម្តេច"ក្នុងជំពូកទី I ដែលចែងអំពីបែបបទ និង របៀបរៀបចំរដ្ឋាភិបាល។

## • កំណើតរបស់រដ្ឋ

រដ្ឋកើតចេញពីការរួមផ្តុំគ្នានៃមនុស្សជាច្រើន។ ក្នុងការរស់នៅដើម្បីជៀសវាងនូវភាពច្របូកច្របល់គ្នាដូចសត្វធាតុ មនុស្សបានបង្រួមឆន្ទៈឱ្យមកតែមួយដើម្បីសំរេចគោលបំណងដែលមនុស្សទាំងអស់ត្រូវគោរពតាម និង ការពារផលប្រយោជន៍រួមរបស់គេ ។ ម្យ៉ាងទៀត ដើម្បីឱ្យមនុស្សប្រព្រឹត្តអំពើល្អ និង ចៀសវាងនូវ អំពើអាក្រក់ មនុស្សបានបង្កើតជាច្បាប់ និង ការដាក់ទណ្ឌកម្មហើយតុលាការ ក៏ត្រូវបង្កើត ឡើងដែរ ដើម្បីការពារយុត្តិធម៌ឱ្យមនុស្សទាំងអស់ ។

## • ទំរង់រដ្ឋ

- លោកបានចែករដ្ឋជាពីរប្រភេទ : សាធារណរដ្ឋ និង ក្សត្របូរី ដែលមានព្រះអង្គម្ចាស់ម្នាក់ជាប្រមុខ ។

- សាធារណរដ្ឋអាចធ្វើឱ្យមានស្ថេរភាព សេរីភាព និង សមភាព ក្នុងសង្គម ។ ចំពោះរាជានិយម ( រាជាធិបតេយ្យ)


www.elibraryofcambodia.org

អាចនាំទៅរក វិសមភាពទាសភាព និងការធ្លាក់ចុះរបស់សង្គម ។ ទំរង់រដ្ឋដែលល្អនោះ គឺ សាធារណរដ្ឋចំរុះ ដែលកើតចេញពីការលាយបញ្ចូលគ្នារវាង រាជាធិបតេយ្យ អភិជនាធិបតេយ្យ និង ប្រជាធិបតេយ្យ ។

## • កំលាំងរបស់រដ្ឋ

- ភាពអាណាធិបតេយ្យបានបំផ្លាញសហគមន៍ទាំងមូលរបស់រដ្ឋ ដើម្បីឱ្យរដ្ឋមួយ មានសណ្តាប់ធ្នាប់ គេត្រូវបង្ខំចិត្ត ធ្វើផ្តុយពីជំនឿសប្បុរសធម៌ មនុស្សធម៌ និងផ្ទុយពីសាសនា ។ វិធានការណ៍ របស់លោកគឺ "ឬមួយបបោសអង្អែល ឬមួយកំទេចចោល" "សុខចិត្តសំលាប់ប្រសើរជាងសំឡុតគំរាមកំហែង ឬព្រមានសត្រូវ" "សុខចិត្តកាចសាហាវឃោរឃៅ ប្រសើរជាងធ្វើចិត្តជាអ្នកល្អ" ពីព្រោះថា កាចសាហាវ នាំឱ្យមនុស្សពាលតិចតួចឈឺចាប់តែបើសន្តោសប្រណីវិញ នឹងនាំឱ្យសង្គមឥតសណ្តាប់ធ្នាប់ ហើយចុងក្រោយនាំឱ្យប្រជាជនរងទុក្ខវេទនា ។

- រដ្ឋត្រូវមានច្បាប់ល្អ ទាហានល្អ និងការគាំទ្រពីប្រជារាស្ត្រ ។ មិនតែប៉ុណ្ណោះ គេអាចវាស់ស្ទង់កំលាំងរបស់រដ្ឋមួយ ដោយពិនិត្យទៅលើកំលាំងមនុស្ស កំលាំងធនធាននិងកំលាំងកងទ័ព ដែលមានសមត្ថភាពអាចការពារទប់ទល់នឹងសត្រូវបាន ។


www.elibraryofcambodia.org

• **អព្យាក្រឹត្យភាពរបស់រដ្ឋ**

- ការឋិតនៅជាអព្យាក្រឹត្យរបស់រដ្ឋមួយ គឺជាគ្រោះថ្នាក់សំរាប់រដ្ឋនោះ (ទំព័រ ១១៨-១១៩-១២០) ។ អ្នកដែលមិនមែនជាមិត្ត ចង់ឱ្យតែអ្នកនៅជាអព្យាក្រឹត្យ ។

• **ការកាន់កាប់រដ្ឋមួយដែលដណ្តើមបាន :**

- ត្រូវរឹបអូសទ្រព្យសម្បត្តិពីប្រជាជនឱ្យអស់ ។
- ត្រូវទៅនៅទីនោះដោយផ្ទាល់ ។
- ទុកឱ្យគេរស់នៅក្រោមច្បាប់ទំលាប់ចាស់របស់គេ ។
- ផ្តល់ជំនួយដល់គេ ។
- តែងតាំងរដ្ឋាភិបាលមួយដែលស្និទ្ធនឹងយើង ។

## ២-គំនិតនយោបាយស្តីពី "សង្គ្រាម"

- នយោបាយត្រូវជាប់ទាក់ទងជិតស្និទ្ធ នឹងសង្គ្រាម ។ សង្គ្រាមគឺជា ការសំដែងឡើងនូវរូបភាពខាងក្រៅរបស់នយោបាយ ។

- សង្គ្រាមគឺជាវិទ្យាសាស្ត្ររបស់អ្នកដឹកនាំគ្រប់គ្រង។ សង្គ្រាមគឺជាសិល្បៈដើម្បីបង្កើត និង រក្សារដ្ឋឱ្យបានគង់វង្ស ។ ក្នុងការធ្វើសង្គ្រាមត្រូវមានកងទ័ពមួយដ៏ខ្លាំងក្លារបស់ប្អូរី មិនមែនកងទ័ពស៊ីឈ្នួលបរទេសឡើយ ។



www.elibraryofcambodia.org

## ៣-គំនិតនយោបាយស្តីពី អ្នកដឹកនាំរដ្ឋ

- នៅចំពោះមុខប្រទេសធំៗ ដែលនៅជិតខាងដូចជា អេស្ប៉ាញ បារាំង និងអង់គ្លេស អ៊ីតាលីអាចនឹងធ្វើការបង្រួបបង្រួមប្រទេសរបស់ខ្លួនបាន និងធ្វើឱ្យប្រទេសរបស់ខ្លួនខ្លាំងក្លាទៅបានដោយមាន "សម្តេច" មួយអង្គជាអ្នកដឹកនាំ ។

- សេចក្តីស្រឡាញ់ របស់ប្រជារាស្ត្រចំពោះអ្នកដឹកនាំរដ្ឋ គឺជា "បន្ទាយថ្ម" ដ៏ល្អបំផុត (ទំព័រ១១៥)។ ដូច្នេះ ត្រូវរក្សាមិត្តភាពជាមួយប្រជាពលរដ្ឋ ។

- "សម្តេច" ត្រូវតែជាបុគ្គលមួយរូបដ៏ខ្លាំងពូកែ អាចធានានូវការឯកភាព អំណាច និងការឯកភាពរដ្ឋ។ ជារួម"សម្តេច"ត្រូវមានលក្ខណៈវិនិច្ឆ័យ ៧ យ៉ាង :

- ទីមួយ : **ភាពប្រាកដនិយម**

ត្រូវប្រកាន់យកភាពប្រាកដនិយមជាគោល ។ ត្រូវគិតពីអ្វីដែលកំពុងធ្វើ មិនត្រូវជឿទុកចិត្តលើអ្វីដែលគេនិយាយប្រាប់យើងទេត្រូវឃ្លាំមើលជានិច្ច មិនត្រូវខ្លាចអ្វីទាំងអស់ ។ ពេលមានអ្វីកើតឡើងមិនត្រូវស្ងន់ស្ងោរ ត្រូវចាត់ទុកជារឿងធម្មតា ។ មិនត្រូវធ្លាក់ក្នុងគំនិត សន្តិភាពនិយមពេកទេ មិនត្រូវជឿលើខ្លួនឯងឱ្យហួសហេតុពេកដែរ ។



www.elibraryofcambodia.org

## ៘ទីពីរ ៖ អត្តទត្ថ និងលើកដំកើងខ្លួន

ជាធម្មតាមនុស្សតែងគិតគូរអំពីផលប្រយោជន៍ផ្ទាល់ខ្លួន ឬលើកដំកើងខ្លួនឯងតាមរយៈការបង្ហាញឱ្យគេស្គាល់នូវសកម្មភាព ឬតាមស្នាដៃរបស់យើង(ទំព័រ២១-១១៧)។ ជាមួយមជ្ឈដ្ឋានអាក្រក់ យើងមិនអាចយកអ្វីដែលល្អទៅប្រើប្រាស់បានទេ (គេមិនអាចចាត់ទុកថាយើងជា អ្នកល្អក្នុងចំណោមមនុស្សអាក្រក់បានទេ) ។

## ៘ទីបី ៖ ត្រូវចេះគន់គូរ

ត្រូវចេះគន់គូរមើលថា បើយកមនុស្សណាម្នាក់មកប្រើ តើវាចំណេញអ្វីខ្លះដល់យើង ។ អ្នកតាមដង្ហែយើង ឬ បំរើយើងដោយឥតលោភលន់គឺត្រូវផ្តល់រង្វាន់ដល់គេ និងស្រឡាញ់គេ ។ ត្រូវយកអ្នកដាច់តែឯង មកធ្វើជាទីប្រឹក្សារបស់យើង ពួកនេះនឹងចេះជួយការពារយើងពេលមានអាសន្ន ។ មនុស្សដែលមិនទាក់ទិននឹងយើងក្នុងគោលការណ៍ណាមួយ គួរកុំយកមកប្រើ ព្រោះមនុស្សប្រភេទនេះ គេគិតអំពីផលប្រយោជន៍គេ ជាងផលប្រយោជន៍យើង ។ នៅពេលមានអាសន្ន ពួកនេះនឹង បំផ្លាញយើង ។ ជាទូទៅ "សម្តេច" ត្រូវធ្វើយ៉ាងណាឱ្យគេខ្លាច និង គោរពយើងជាជាងឱ្យគេស្រឡាញ់យើង(ទំព័រ៩០) ។


www.elibraryofcambodia.org

-ទីបួន ៖មិនត្រូវចាប់អារម្មណ៍អើពើទៅលើអ្វីដែលល្អ អ្វីដែលអាក្រក់ទេ ប៉ុន្តែត្រូវចេះប្រើប្រាស់នូវសកម្មភាពទាំងពីរ (អំពើទាំងពីរ) នៅពេលណាដែលកាលៈទេសៈតំរូវឱ្យ ។ គោលដៅបញ្ជាក់ឡើងនូវ មធ្យោបាយដែលប្រើប្រាស់ ។

-ទីប្រាំ ៖ **ត្រូវមានភាពប៉ិនប្រសប់**

ត្រូវចេះប្រើល្បិច ពីព្រោះអ្វីៗ ទាំងអស់ តែងតែមានសភាពគានតឹងជានិច្ច មុននឹងឈានទៅដល់គោលដៅ ។ ល្បិចកលដែលប្រើប្រាស់គឺ "បំបែកបំបាក់ដើម្បីត្រួតត្រា" ។

-ទីប្រាំមួយ ៖ **ត្រូវចេះដើរតួ**

ត្រូវចេះលាក់អាថ៌កំបាំង ឬលាក់ពុតយ៉ាងប៉ិនប្រសប់ ។

-ទីប្រាំពីរ ៖ **ត្រូវមានអានុភាព**

ត្រូវមើលឃើញខ្លួនយើងឋិតនៅពីលើគេទាំងអស់ ។


www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកហ្សង់បូដាំង

# ១៥៣០-១៥៩៦ គ.ស

# (Jean Bodin)

## I. ជីវិតនិងបុគ្គលិកលក្ខណៈ



-លោកកើតនៅអង់ហ្សេ ហើយឋិតក្នុងគ្រួសារនៃវណ្ណៈមធ្យម ។

-លោកបានរៀនសូត្រពីផ្នែកច្បាប់នៅទូលូ ដែលជាទីក្រុង ដ៏សំខាន់ នៃជីវិត របស់លោក ហើយលោក បានក្លាយទៅជាសាស្ត្រាចារ្យ ផ្នែកច្បាប់ (ច្បាប់រ៉ូម៉ាំង) ។

- លោកក៏ជាសេដ្ឋវិទូ ប្រវត្តិវិទូ និង ជាអ្នកគិតគូរខាងផ្នែកនយោបាយដែរ ។ លោកជាតំណាងរាស្ត្រនៅរដ្ឋប្លឺរ ។



www.elibraryofcambodia.org

- លោកបានទាក់ទងជិតស្និទ្ធជាមួយបងរបស់ស្តេចហង់រីទី III ហើយបានចូលទៅបំរើការងារក្នុងផ្នែកច្បាប់នៃរដ្ឋាភិបាល ។

- លោកបានរស់នៅចំពេលដែលប្រទេសបារាំង បានទទួលការឯកភាពទឹកដី ប៉ុន្តែ នៅមានទំនាស់ផ្នែកសាសនា ដែលចាប់ផ្តើមតាំងពីឆ្នាំ១៥៦២ ហើយបន្តរហូតដល់ ពេញមួយជីវិតរបស់លោកក្នុង ស.វទី១៦ ។

- លោកត្រូវបានគេទទួលស្គាល់ថា ជាអ្នកទ្រឹស្តីនយោបាយដ៏ល្បីល្បាញមួយរូប ។

- លោកបានទទួលមរណភាពនៅឡាអុងក្នុង ឆ្នាំ១៥៩៦ ។

## II.ស្នាដៃ

- ស្នាដៃផ្តើមរបស់លោកមានឈ្មោះថា "រដ្ឋ" (៦ក្បាល) ដែលត្រូវចេញផ្សាយជាសាធារណៈ ។

- ស្នាដៃផ្តើមរបស់លោកមួយទៀតមានឈ្មោះថា "សេចក្តីរាយការណ៍ស្តីពីច្បាប់សកល" ។

## III.គំនិតនយោបាយសំខាន់ៗ

### ១-អធិបតេយ្យភាព


www.elibraryofcambodia.org

លោកគឺជាជនដំបូងគេបង្អស់ ដែលបានកំណត់ន័យស្តីពី"អធិបតេយ្យភាព" ។ លោកបានចាត់ទុកថា អធិបតេយ្យភាព ជាអំណាចផ្តាច់មុខ និង ស្ថិតស្ថេរជាប់ជានិច្ចរបស់រដ្ឋ ។ នេះគឺជាអំណាចធំបំផុតសំរាប់បញ្ជា ។ អធិបតេយ្យភាព គឺជាឯករាជ្យភាពរបស់រដ្ឋផ្តាច់ចេញពីសម្តេចប៉ាប ពីព្រះវិហារ ពីអធិរាជ និងឯករាជ្យចេញពីរដ្ឋដទៃ ។ អធិបតេយ្យភាព ឋិតថេរយូរអង្វែងជាមួយរដ្ឋ ហើយមិនគិតពីការ ផ្លាស់ប្តូររូបភាពរបស់រដ្ឋាភិបាល ។ រដ្ឋមានអធិបតេយ្យភាពលុះត្រាតែ រដ្ឋនោះ មិនមែនជាកម្មវត្ថុនៃអំណាចរបស់រដ្ឋមួយផ្សេងទៀតឡើយ ហើយទំនាក់ទំនងជាមួយរដ្ឋដទៃ ត្រូវប្រកាន់យកដោយស្របទៅតាមច្បាប់របស់ប្រទេស និង អន្តរជាតិ ។

## ២-រដ្ឋ

អំណាចរដ្ឋ គឺជាអំណាចរបស់គ្រប់ពលរដ្ឋទាំងអស់ ។ គ្រួសារគឺជាធាតុចំបង និងជាកោសិការបស់រដ្ឋ។ រដ្ឋជាកន្សោមនៃគ្រួសារដ៏ច្រើនរួមផ្គុំគ្នា។ រដ្ឋមិនអាចស្មើនឹងបុគ្គលម្នាក់បានឡើយ។អំណាចរបស់រដ្ឋ គឺជាអំណាចឋិតថេរនិងផ្តាច់មុខ ។ រដ្ឋគឺជាអំណាចកំពូលនិងឯករាជ្យ ទាំងក្នុងផ្ទៃប្រទេស ទាំងក្នុងទំនាក់ទំនងអន្តរជាតិ ។

## ៣-របបរបស់រដ្ឋ

របបរបស់រដ្ឋ ផ្តល់ឱ្យដោយអធិបតេយ្យភាពរបស់រដ្ឋ ។


www.elibraryofcambodia.org

● **របបរដ្ឋមានបីគឺ :**

- របបដែលឋិតក្នុងកណ្តាប់ដៃរបស់ព្រះរាជាមួយអង្គ : គឺជា **រាជាណាចក្រ** ។

- របបដែលឋិតក្នុងកណ្តាប់ដៃប្រជាពលរដ្ឋ : គឺជារបប **ប្រជាធិបតេយ្យ**។

- របបដែលឋិតក្នុងកណ្តាប់ដៃមនុស្សមួយក្រុម : គឺជា របប **អភិជនាធិបតេយ្យ** ។

លោកបានបដិសេធ ចំពោះរបបចំរុះ ពីព្រោះ លោកយល់ថា របបនេះនឹងមានទំនាស់ផ្ទៃក្នុងដោយសារតែការបែងចែកអំណាច។



www.elibraryofcambodia.org

# គំនិតនយោបាយរបស់លោកថូម៉ាស់ហូបស៍

# ១៥៨៨-១៦៧៩

# (Thomas Hobbes)

## I.ជីវិតនិងស្នាដៃ



- លោកហូបស៍កើតនៅ ម៉ាល់ម៉េសប៊ូរី ក្នុងឆ្នាំ១៥៨៨ ។
- ឪពុករបស់លោកជាភូ្លឈ្មួយ ទីទ័លក្រម្នាក់ ។
- ឪពុករបស់លោក ត្រូវគេបំបែរបង់ដោយសារ មានទំនាស់ ជាមួយអាចារ្យរបស់ សាសនាគ្រឹស្ត ។



www.elibraryofcambodia.org

# ឯកសារពិគ្រោះ

* ឯកសារជាភាសាខ្មែរ

• ឆយ យីហ៊ាង ***ប្រវត្តិទស្សនវិជ្ជាបស្ចិមប្រទេស*** ឯកសារប្រើប្រាស់ផ្ទៃក្នុងឆ្នាំ១៩៩៤ ។

• ម៉ាកាវែល្លី នីកូឡូ ***សម្ដេច*** បកប្រែជាភាសាខ្មែរដោយបណ្ឌិត ឃូ គិមទូយ ឆ្នាំ ១៩៩៦ ។

• ឈុន ណារ៉េត ***ទ្រឹស្ដីវិទ្យាសាស្ត្រនយោបាយ*** ឆ្នាំ២០០៥

• ឈុន ណារ៉េត ***ប្រវត្តិគំនិតនយោបាយ និង ទ្រឹស្ដីរដ្ឋ*** ឆ្នាំ២០០៧ ។

• រស់ ចន្ត្រាបុត្រ ឯកសារបង្រៀនជាភាសាបារាំង ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ នៅរាជបណ្ឌិតសភាកម្ពុជា ឆ្នាំ២០០០ ។

• សុខ គាង ***វិទ្យាសាស្ត្រនយោបាយ*** ភាគ១ ឆ្នាំ២០០២ ។


www.elibraryofcambodia.org

* ឯកសារជាភាសាបរទេស


• Belasco J.Milton ***Basic World History*** , Cambridge book company , inc. Bronxville , New York 1959 .

• Dubouchet Paul ***Histoire des Idées Politiques*** Tome I , 1ère Edition, 1990

• Ebenstein Alan & Ebenstein William ***Great Political Thinker*** , sixth Edition, 2000

• Glotz Gustave ***La cité grecque*** Editions Albin Michel , 1968

•Russ Jacqueline ***Histoire de la Philosophie De Socrate à Foucault*** , Hatier Paris Janvier 1985 .

• Sargent Tower Lyman ***Contemporary Political Ideologies*** Brooks/Cole Publishing Company , seventh Edition1987

• Stirba P.James ***Social and Political Philosophy*** , Wadsworth Publishing Company 1995




www.elibraryofcambodia.org

08200693 006066 082006

www.elibraryofcambodia.org

www.elibraryofcambodia.org